# វេរ្យការស្តេចនរោត្តមសីហនុ (ភាគទី ១)

គេសរសេរ ប្រវត្តិសាស្ត្រ ថយក្រោម ក៏ប៉ុន្តែ ជីវិតប្រវត្តិសាស្ត្រ ឈានដើរទៅមុខ ។ History was written backwards, but lived forwards. ។ ឧទាហរណ៍ សន្ធិសិទ្ធ ស្ហ៊ីណែវ ១៩៥៥ (Geneva Peace Agreement on Indochina 1955) ជាព្រឹត្តិការប្រវត្តិសាស្ត្រ សំខាន់មួយ ។ ដូច្នេះសន្ធិសិទ្ធស្ហ៊ីណែវ នេះកើតមាន រួចស្រេចទៅហើយ បន្ទាប់មក ប្រវត្តិសាស្ត្រវិទូ ស្រាវជ្រាវរក ព្រឹត្តិការណ៍ ដែលរុញច្រាន បណ្តាល ឲ្យកើតមាន សន្ធិសិទ្ធ ស្ហ៊ីណែវ ១៩៥៥ ហើយនិង ហេតុផល់ ដែលហូរចេញអំពី ស្ហ៊ីណែវ ១៩៥៥ នេះ ។

សន្ធិសញ្ញា ស្ហ៊ីណែវ ១៩៥៥ បានធ្វើឲ្យ ប្រទេសកម្ពុជា បាត់បង់ ខេត្តខ្មែរ មាត់ជ្រូក ក្រមួនស ស្វាយទង់ ឡុងហៃ ឡាំសឹង តាន់សុនញឹក ទៅយួន ក្នុងរជ្យកាលស្តេចសីហនុ ។ មុន សន្ធិសញ្ញា ស្ហ៊ីណែវ ១៩៥៥ ខេត្តខ្មែរទាំងអស់នេះ ស្ថិតនៅក្នុង ការគ្រប់គ្រងនៃ ស្តេចសីហនុ នៅឡើយទេ ។

តាំងតែពី ស្តេចសីហនុ លោកនៅរៀន សាលាវិទ្យាល័យព្រៃនគរ (Chasse Loup Laubart) ទីប្រឹក្សារយួនហាណូយ តែងតែនិយាយ បញ្ចុះបញ្ចូល ពន្យល់ ស្តេចសីហនុ ថាវៀតណាមមានពីរ ÷ វៀតណាមខាងត្បូង ជាយួនអាក្រក ដើរជិះជាន់ រំលោភយក ទឹកដីខ្មែរ ចំណែកឯ វៀតណាម ខាងជើង ជាវៀតណាមល្អ ជួយប្រទេស ជិតខាង ជួយខ្មែរ ជួយលាវ វាយបារាំង ដើម្បី ទាមទារ ឯករាជ្យ ។

ស្តេចសីហនុ ជឿថា វៀតណាម ខាងជើង មុខតែឈ្នះសង្គ្រាមនៅថ្ងៃមុខ ដូច្នេះ លោកត្រូវ តែចូលជា មួយអ្នកឈ្នះសង្គ្រាម ។ ដើម្បីនិងឈ្នះ ជាមួយយួនហាណូយ ស្តេចសីហនុ សំរេចចិត្ត គាំទ្រ យួនហាណូយ ។ ស្តេចសីហនុ ជឿថា យួនហាណូយ ស្មោះត្រង់និងលោក ។ លោកជឿថា បើលោកជួយ យួនហាណូយ ឲ្យឈ្នះ ដល់ពេល

យួនហាណូយឈ្នះ យួនហាណូយ មុកតែ ដឹងគុណលោក ជាមិនខាន ។ លោកជឿថា យួនហាណូយ និងរំដោះ កម្ពុជាកណ្តាល ហើយ រួចទៅ យួនហាណូយនឹង ទុកឲ្យ ស្តេចសីហនុ សោយរាជ្យ គ្រប់គ្រងព្រះរាជអាណាចក្រខ្មែរ តទៅ ទៀត ដោយសុខក្សេមក្សាន្ត ។ ស្តេចសីហនុ ជឿ ការឃោសនានៃ យួនហាណូយ ថាយួនហាណូយជាយួនល្អ ចំណែកឯ យួនខាងត្បូង ជាយួនអាក្រក់ ។

អ្វីដែលខុសធំ ក្នុងការជ្រើសរើស ផ្លូវនយោបាយ នៃស្តេចសីហនុខាងលើនេះ គឺ ស្តេចសីហនុ ពឹងផ្អែក ទាំងស្រុង ទៅលើកម្លាំងបរទេស លោកមិនគិត ខិតខំកសាង កងទ័ពជាតិ ឲ្យខ្លាំងពូកែរ ហើយយក កម្លាំងជាតិ ជាស្នូល ។ ស្តេចសីហនុ ហើយនិង មេដឹកនាំខ្មែរ ភាគច្រើន នាំគ្នាគិតថា វៀតណាម ខ្លាំងពូកែរណាស់ ខ្មែរយើងមិនអាច ប្រឆាំង តទល់តាម អាវុធប្រឆាំង និងវៀតណាមបានទេ ។ បើយើងជឿដូច្នេះមែន គឺ យើងនាំគ្នា អោនក្បាលឲ្យ វៀតណាម សម្លាប់យើង តាមតែ ទំនើងចិត្តគេ ។ បើវាពិត ដូច្នេះមែន ហេតុអ្វី ក៏ប្រទេសចិនមិន ជិះជាន់ វៀតណាម ដូចវៀតណាម មកជិះជាន់ ប្រទេសខ្មែរ ដែរទៅ ? ប្រទេសវៀតណាម ជាប្រទេស តូចមួយទេតើ បើយើង ធាបប្រៀប វៀតណាម ជាមួយនិងប្រទេសចិន ។ ដូច្នេះ បើប្រទេស វៀតណាម អាច ប្រឆាំងតទល់ ជាមួយចិនបាន ហេតុអ្វី ក៏ខ្មែរមិនហ៊ាន តទល់ និងយួន ក្នុងការជិះជាន់លេប ទឹកដីខ្មែរ ? ហេតុអ្វីក៏ខ្មែរ មិនទាន់បានអ្វីផង នាំគ្នាចុះញ៉ម សូមចាញ់គេ តែម្តងទៅហើយ ?

ស៊ុនស៊ឺ មេទ័ពចិន និយាយថា គ្មានជ័យជំនះ អ្វីប្រសើរជាង ជ័យជំនះ ដែលបាន មកពីការដាក់អាវុធ ដោយឥតហ៊ានច្បាំង នៃកងទ័ពសត្រូវទេ គឺថាសត្រូវជឿជាក់ក្នុងចិត្តថា វាអស់ផ្លូវហើយ ហើយជឿជាក់ថា បើ បន្តការ ច្បាំង តទៅទៀត វាឥតមានប្រយោជន៏អ្វីទេ វាគង់តែចាញ់គេ ដដែល ! នេះហើយដែលយួន គេចង់ ឲ្យខ្មែរជឿក្នុងចិត្តថា មិនបាច់ ច្បាំងតតាំងអ្វីទេ ធ្វើយ៉ាងណាក៏ដោយ ក៏ចាញ់យួនទៅហើយ ។

យើងត្រូវតែកំចាត់ចោលចេញគំនិតចាញ់គេ គំនិតសន្តិភាពនិយម ពិខ្លួនយើងម្នាក់ៗ!

អៀងសារី ក៏ជឿស្អិប ដូចគ្នានិងស្តេចស៊ីហានុ ថាយួនហាណូយ ជួយរំដោះ កម្ពុជាក្រោម អំពីអាណានិគម បារាំង ហើយនិងចក្រព័ត្រ អាមេរិកាំង ហើយ អៀងសារី ជឿថា យួនហាណូយ នឹងទុកឲ្យ អៀងសារី គ្រប់គ្រងកម្ពុជាក្រោម ។ អៀងសារីជឿថា មានតែ យួនខាងត្បូងទេ ដែលជា យួនលេបទឹកដីខ្មែរ ។

នៅពេលនោះ ឆ្នាំ ១៩៥៦ អៀងសារីជាជនសមញ្ញ ចំណែកឯ ស្តេចស៊ីហានុ ជាស្តេចគ្រប់គ្រង ដែនដី ។ ស្តេចស៊ីហានុ លោកជាអ្នកទទួល ខុសត្រូវ ចំពោះវាសនាជាតិ ។

ស្តេចស៊ីហានុ មិនដែលយល់ថា យួនទាំងពីរនេះ វាដូចគ្នាទេ លោក មិនដែលយល់ថា យួនទាំង ពីរនេះ វាចង់លេបទឹកដីខ្មែរ ដូចគ្នា វាកាប់សម្លាប់ ធ្វើបាប ខ្មែរ ដូចគ្នា ។

នយោបាយជឿស្អិប លើយួនហាណូយ នៃស្តេចស៊ីហានុ នេះឯងហើយ ដែលជា មហន្តរាយ សម្លាប់ជាតិខ្មែរ ។

ទស្សនៈវិទូ នយោបាយ ប៉ាល់ម័រស្តូន (Palmerstone) សរសេរថា ការប្រាស្រ័យទាក់ទង រវាងប្រទេសជាតិ និមួយៗ ឈរទាំងស្រុង នៅលើ គោលជំហ៊រប្រយោជន៏ៗ គ្មានប្រទេសណាជាមិត្ត របស់ប្រទេសណាទេ ។ អ្វីដែលសំខាន់បំផុត ក្នុងការទាក់ទង រវាងប្រទេស គឺ ផល់ប្រយោជន៏ ។ មានតែផលប្រយោជន៏ទេ ដែលសំខាន់ជាងគេបំផុត ។ គ្មានអ្នកណាដឹងគុណអ្នកណាទេ ។ បើប្រទេសមួយ គេមានផលប្រយោជន៏និងធ្វើជាមិត្ត ពេលនោះ ប្រទេសនោះ គេនិងយក នយោបាយមិត្តភាពជាត្រីមុខៗ ជាទូទៅ ប្រទេសនិមួយៗមានចិត្តជា ទេវទត្តតែមាត់ជាទេវតា ~ មិត្តភាពតែបបូរមាត់ ។ ពេលណាគេ យល់ថា គេមាន ប្រយោជន៏និងលេបទឹកដីនៃប្រទេសមួយទៀត នៅពេល នោះ គេនិង វាយបន្លុំប្រទេសនោះ ដោយឥតអាណិតអាសូរ ហើយលេប យកទឹកដីប្រទេសនោះ ដោយគ្មាន អាលោះអាល័យ ។ ដូច្នេះ មិត្តនៅថ្ងៃនេះអាចក្លាយទៅជា សត្រូវនៅថ្ងៃស្អែក ហើយសត្រូវថ្ងៃនេះ អាចក្លាយ ទៅជាមិត្ត

នៅថ្ងៃស្អែក ។ ប្រទេសនិមួយៗ ប្រៀបបានទៅសត្វ ដ៏កំណាចមួយ គ្មានយោគយល់ គ្មានបង គ្មានប្អូន គ្មានអាណិតអាសូរ ហើយប្រុងប្រៀបខ្លួន ជានិច្ច និងត្របាក់ លេបយក ប្រទេស មួយទៀត ប្រសិនបើលេបបាន ។

ដោយហេតុតែ ស្តេចស៊ីហនុ គាំទ្រ នយោបាយយួនហាណូយ នេះឯងហើយ ទើបបានជា លោកលែងមើលយល់ អ្វីទាំងអស់ អ្វីដែលជា អ្នកស្នេហាជាតិពិតប្រាកដ ។ ដោយលោក ជឿពាក្យមួល បង្កាច់ នៃពួក យួនហាណូយ លោក បែរជា យកអ្នកស្នេហា ជាតិ ជាសត្រូវ របស់លោក ទៅវិញ ។ លោកមិនទុកចិត្តលើកម្លាំងជាតិ ឯងទេ លោកពឹង ផ្អែកទៅលើ កងទ័ព យួន ឬ ចិន ដើម្បី ការពារនយោបាយ របស់លោក ។ ដូចជា ចលនា ខ្មែរឥស្សរៈ ហើយនិង ចលនាកន្សែងស ដែលវាយយួន ឲ្យចេញ អំពី ប្រទេសខ្មែរ ត្រូវស្តេច ស៊ីហនុចាត់ ទុកជា ក្បត់ជាតិ ។ សព្វថ្ងៃនេះទៀត សូម្បី អង្គរក្ស របស់លោក សុទ្ធតែ ជនជាតិ កូរ៉េកុម្មុនិស្តទាំងអស់ ។ ដោយលោកជឿតាម នយោបាយ យួនចិន កុម្មុយនិស្ត លោករៀបចំសេដ្ឋកិច្ចខ្មែរ តាម សង្គមនិយម នេះជាហេតុ បណ្តាលឲ្យ សេដ្ឋកិច្ចខ្មែរ ហិនហោច អន្តរធានអស់រលីង ។ ពួកសេរីនិយម ស្នើ យោបល់អ្វី មិនបានទេ ត្រូវស្តេច ស៊ីហនុ ចោទថា ក្បថជាតិ ។

នៅពេលដែលខ្មែរយើង បាត់បង់ទឹកដីកម្ពុជាក្រោម វៀតណាម និយាយកំញើញ ប្រមាថ ស្តេចស៊ីហនុ ហើយនឹង អ្នកដឹកនាំខ្មែរថា វាជ្រុលទៅ ហើយៗ ឥឡូវនេះ យួនគេ ឲ្យសុខយើង ។ ចូរខ្មែរយើងកុំចង់កកូរកកាយ ឲ្យខូចសុខដុមរមនា ដែលយួន គេអនុញ្ញាត្តិឲ្យ ។ ចូរកុំតវ៉ា ទាមទារ យកទឹកដីខ្មែរ មកវិញធ្វើអ្វី វារើមិនរួចទេ ។ បើអ្នកណា មួយ ហ៊ាន និយាយ តវ៉ា យួននិងបញ្ជាឲ្យខ្មែរ អ្នកកាន់រដ្ឋអំណាច យកខ្មែរអ្នក តវ៉ា យកទៅ ដាក់ គុក ឬ សម្លាប់ចោល ។

រឿងដដែលនេះ កើតមាន ត។ ឥតឈប់ឈរ នៅកម្ពុជាកណ្តាល ។ ហេងសំរិន ជាស៊ីម បានស៊ីញ៉េ តាងនាមនៃរដ្ឋកម្ពុជា ហើយនិង ក្នុងនាមនៃ គណៈប័ក្សកុម្មុយនិស្តខ្មែរ សន្ធិសញ្ញា ឆ្នាំ ១៩៧៩, ១៩៨២, ១៩៨៥ និង ១៩៨៧ ផ្ទេរអំណាចគ្រប់គ្រង ទឹកដីខ្មែរ ប្រហែល មួយភាគបី ឲ្យទៅវៀតណាម ។

បន្ទាប់មក ស្តេចខ្មែរ រាជរដ្ឋាភិបាលខ្មែរ មិនហ៊ានប្រកាស់បដិសេធចោល សន្ធិសញ្ញា ឆ្នាំ ១៩៧៩, ១៩៨២, ១៩៨៥ និង ១៩៨៧ ខាងលើនេះទេ ថ្វីបើ សន្ធិសញ្ញា អន្តរជាតិ ១៩៩១ នាក្រុងប៉ារីស ជំរុញឲ្យ រដ្ឋភិបាលខ្មែរ បដិសេធចោល សន្ធិសញ្ញា ទាំងអស់ខាងលើ នេះ យ៉ាងណាក៏ដោយ ។

សេចក្តីពិនា ខាងលើនេះ បង្ហាញឲ្យឃើញថា ស្តេចខ្មែរ រាជរដ្ឋាភិបាល ទាំងអស់ តាំងតែ ពីឆ្នាំ ១៩៩៣ មកទល់ សព្វថ្ងៃនេះ ចុះញ៉មយួន ចូលដៃយួន។ ស្តេចខ្មែរ រដ្ឋភិបាល ខ្មែរ ឃ្លានអំណាច សន្តិភាពនិយម មិនហ៊ាន ប្រកាស់ បដិសេធចោល  សន្ធិសញ្ញា ក្បត់ជាតិ ឆ្នាំ ១៩៧៩, ១៩៨២, ១៩៨៥ និង ១៩៨៧ ខាងលើនេះទេ ។ យើងមិន មែន បង្ខំឲ្យកែនគ្នា ទៅ ធ្វើសង្គ្រាមវ៉ៃយួន ដណ្តើមយកទឹកដីខ្មែរ មកវិញភ្លាមទេ ។

យើងយល់ ឃើញថា យ៉ាងហោចណាស់ ខ្មែរត្រូវតែ ប្រកាស់ ការពារព្រំដែន ទឹកដីអាកាស់ខ្មែរ តាម ផ្លូវច្បាប់ ។ រដ្ឋភិបាលខ្មែរត្រូវតែ ប្រកាស់ជា ឧឡារិក ដាក់ពាក្យ ប្រកាស់ជាផ្លូវការ ផ្តឹងដំកល់ទុកនៅ ស្ថាប័នអន្តរជាតិនានា ការពារ តាមផ្លូវ ច្បាប់ ទឹកដីអាកាស់ខ្មែរ ។

កាលពី ១៩៦២ ស្តេចស៊ីហានុ បាន ផ្តឹងតវ៉ា ជាមួយរដ្ឋភិបាល អាមេរិកាំង កេណឺឌី (President John Fitzgerald Kennedy) សូមឲ្យ រដ្ឋភីបាលអាមេរិកាំង ជួយធ្វើអន្តរាគមន៏ ដើម្បី ឲ្យទឹកដី កម្ពុជាក្រោម វិលត្រឡប់មកខ្មែរវិញ ។ មរណភាពនៃ លោក កេណឺឌី បានធ្វើឲ្យ ស្ពាក់ស្ទះ ការតវ៉ានៃស្តេចស៊ីហានុ ដើម្បីទាមទាយក ដែនដីកម្ពុជា ក្រោម

មកខ្មែរវិញ នៅពេលនោះទៅ ។ <<American policy about Cambodia and Kampuchea Krom during Vietnam War. Especially from Khmer sources.>> would be a good topic for scholar research.

នៅកម្ពុជាក្រោម ក៏ដូចជាកម្ពុជាកណ្ដាល អ្នកណាមួយក៏ចង់សុខដែរ អ្នកណាក៏មិនចង់តវ៉ាអ្វីទេ បើពិតជាបានសុខដូច យួន សន្យា ឯចឹងមែន ក៏ប៉ុន្តែ ខ្មែរ មិនដែលបានសុខទេ ។ ខ្មែរនៅបានសុខ មិនយូរប៉ុន្មានទេ យួនចេះតែ បង្កើតច្បាប់ឯចេះ ច្បាប់ឯចុះ ហាមឃាត់ ទាល់តែខ្មែរយើង វេទនា រសនៅ មិនបាន ។ យួនធ្វើបាប ទាល់តែខ្មែរយើង នាំគ្នារត់ចោលស្រុក នាំគ្នាលួច រត់ដោយលួចលាក់ ពីព្រោះបើយួនដឹង យួននឹងសម្លាប់ចោលទាំងពូជ ។ ម្លោះហើយ ខ្មែរក្រោមរត់មក បាតដៃទទេ បោះបង់ចោល ទ្រព្យសម្បត្តិទាំងអស់ ខំរត់ទៅ ពួនសម្ងំ នៅតាម ទីកន្លែងណា ដែល មានដីទំនេរ គឺថា នៅលើដែនដីខ្មែរ នៅតាមព្រំ ប្រទល់ដែន ខ្មែរយួន ដែល យួនទើប តែ ធ្វើបាបខ្មែរ កាប់សម្លាប់ខ្មែរ ដេញខ្មែរ យកដីខ្មែរ មកដាក់ជា ដីយួន ។ គឺថា នៅ តាមព្រំដែន តាកែវ, ស្វាយរៀង, ព្រៃវែង, កំពង់ចាម ដែលយួន ធ្វើបាប ដេញខ្មែរ នៅកន្លែងនេះ មិនឲ្យ រសនៅកើត ។

ឥឡូវនេះ ខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង យួនចាត់ ទុកជាខេត្តយួនអស់ទៅហើយ ដោយគេចាក់រុក បោកប្រាស់ បងប្អូន ខ្មែរភាគតិច ភ្នង គួយ រ៉ាដេរ ចារ៉ាយ ពិរ កូឡា ម៉ុង ~ យួនបញ្ឆោតពួកបងប្អូន ភាគតិចនេះថា យួន ប្រគល់ឯករាជ្យ ឲ្យទៅបងប្អូនទាំងអស់នេះ ឲ្យដាច់ចេញពីកម្ពុជា ហើយឲ្យ ធ្វើជា ម្ចាស់ការ ខ្លួនឯង ។

បីបួនឆ្នាំក្រោយមក ខ្មែរក្រោម ដែល រស់នៅលើដីខ្មែរ តាមព្រំដែនខាង លើនេះ ត្រូវយួន ដេញចេញ តៗទៅទៀត ឲ្យទៅចាប់ ដីខាងខេត្តបាត់ដំបង ជាប់ព្រំដែនសៀម ។ យួនចេះ តែដេញខ្មែរ តៗគ្នា គ្រប់ជំនាន់ ឥតមានឈប់ឈរឡើយ ។ នេះហើយ ទុក្ខវេទនា នៃបងប្អូនខ្មែរយើង ។ លុះដល់ក្រោយពី ឆ្នាំ ១៩៥៥-៥៦ ខ្មែរក្រោម ភៀសខ្លួន រត់តម្រង់ទៅ

ជ្រក នៅ តាមខ្មែរក្រោមដែល រត់មកជំនាន់មុន នៅតាមខេត្ត បាត់ដំបង សៀមរាប ពោធិសាត់ កំពង់ធំ  ហើយនិង ត្រាត បូរ៉ៃម សូរិន ។

# បើយើង អង្វរករយួន សូមសុខ យួនក៏មិនឱ្យយើងសុខដែរ

បើមិនតវ៉ា ក៏មិនបានសុខ បើតវ៉ា ក៏មិនបានសុខដែរ ។ ហេតុដូច្នេះហើយ មេដឹកនាំខ្មែរក្រោម ប្ដេជ្ញាចិត្តថា ត្រូវតែ តវ៉ា ប្រចាំងយួន វាគ្រាន់បើ ជាជាង ធ្វើស្លូត សូមយួនរស។ បើយើងតវ៉ា វាពិតប្រាកដហើយ មានខ្លះត្រូវបាត់បង់ជីវិត ក៏ប៉ុន្តែ មាន ខ្លះសេសសល់នៅរស ។  ពួកសេសសល់ នៅរស់នេះ និងអាចបន្ត ពូជពង្សខ្មែរ វប្បធម៌ខ្មែរ អារ្យធម៌ខ្មែរ ដើម្បីឲ្យខ្មែរជំនាន់ក្រោយអាចរស់ស្រួល ជាជាងទុក ឲ្យយួនសម្លាប់ខ្មែរយើង ស្រេចតែចិត្តវ៉ា ។

ឆ្នាំ ១៩៧៩ មានកូនខ្មែរកាត់យួន ដែលឪពុកជាខ្មែរ ត្រូវយួនហាណូយ បញ្ជូនមកឲ្យវាយខ្មែរក្រហម ។ ឪពុកខ្មែររបស់គាត់ ត្រូវយួនកៀរ យកទៅស្រុកយួន កាលឪគាត់ នៅជាកុមារ ក្នុងឆ្នាំ ១៩៥៥ ។ ម្ដាយគាត់ជា យួនហាណូយ ។ ក្នុងចំណោម ពួកកូនខ្មែរ កាត់យួនទាំងអស់នេះ មានខ្លះរៀនសូត្រ បានខ្ពង់ខ្ពស់ កាន់មុខដំណែង ជា មេទ័ពយួន ។

ពួកមេទ័ពខ្មែរកាត់យួននេះ និយាយប្រាប់ មេដឹកនាំ ខ្មែរតស៊ូ យើងថា សូមបងប្អូនខ្មែរយើង កុំរត់ចោលស្រុក ត្រូវតែ បងប្អូនខ្មែរយើង នៅក្រាញ តស៊ូរការពារ ទឹកដី ខ្មែរយើង។ យួនគេមកនេះ គេមិនមកជួយខ្មែរយើងទេ គេមកយក ស្រុកខ្មែរយើងហើយ ។ ពួកនេះមានខ្លះមិនចេះនិយាយខ្មែរផងទេ ក៏ប៉ុន្តែ នៅចងចាំពាក្យ បណ្ដាំ នៃឪពុកខ្មែរគាត់ ។

# កម្ពុជាក្រោម

ថ្ងៃទី ៤ មិថុនា ឆ្នាំ ១៩៤៩ ប្រទេសបារាំង បានផ្ទេររដ្ឋអំណាចគ្រប់គ្រង នៃដែនដីកម្ពុជាក្រោម ឲ្យទៅស្ដេចយួន បៅដាយ កាន់កាប់ជុំនួសស្ដេចខ្មែរ នរោត្តមសីហនុ ។ ការណ៍ផ្ទេរ ដែនដី កម្ពុជាក្រោមឲ្យទៅយួន នៃរដ្ឋាភិបាលបារាំងនេះ អនុវត្តិធ្វើឡើង ដោយ

គ្មានមូលដ្ឋានច្បាប់ត្រឹមត្រូវ ដោយគ្មានការសម្រេចដាច់ខាតឯកច្ឆ័ន្ទ តាមមាគ៌ា ប្រជាមតិ នៃប្រជានុរាស្រ្ត ដែលរស់នៅលើ ដែនដីកម្ពុជាក្រោមនោះទេ ។ ស្តេចស៊ីហនុ ព្រះអង្គ មិនបានតវ៉ា ឲ្យយ៉ាងអង្គអាច ប្រឆាំង និងអាណានិគមបារាំង ក្នុងរឿងកម្ពុជាក្រោមនេះទេ លោកប៉ែរជា ហាមឃាត់ រាជរដ្ឋាភិបាលដឹកនាំដោយ លោក ឈាមវ៉ម នៃគណបក្ស ប្រជាធិបតេយ្យ ដែលមក ទីក្រុងប៉ារីស តវ៉ាសូមឲ្យបារាំង ប្រគល់កម្ពុជាក្រោម ឲ្យមក ខ្មែរវិញ ។ បារាំងបង្ខំស្តេច ស៊ីហនុ ឲ្យលោកបញ្ជា ឲ្យគណប្រតិភូរខ្មែរ វិលត្រឡប់ទៅ ស្រុកខ្មែរវិញ បង្ខំរដ្ឋាភិបាលខ្មែរ ឲ្យបញ្ឈប់ ការតវ៉ា ទាមទារយក ទឹកដីកម្ពុជាក្រោម ។ គណរដ្ឋមន្រ្តី ឈាមវ៉ម ត្រូវស្តេចស៊ីហនុ រំលាយចោល ។ ជាទីបញ្ចប់ ស្តេចស៊ីហនុ បែរទៅ អោបពួកយួនកុម្មុយនិស្ត យកចិត្តយួន ពឹងយួនដើម្បី ទាមទារ ឯករាជ្យខ្មែរទៅវិញ ។

អាណានិគម បារាំង បានប្រកាស់ នៅ ថ្ងៃទី ៤ មិថុនា ឆ្នាំ ១៩៤៩ ផ្ទេររដ្ឋអំណាចត្រួតត្រា អំពីខ្មែរ ឲ្យទៅយួន តែខេត្តពីរទេ គឺ ខេត្តព្រះលាវ (ហៅ ខេត្តបាសាក់ ~ ទឹកខ្មៅ) ខេត្តព្រះត្រពាំង ~ព្រៃនគរ (ហៅខេត្តត្រាញ៉ុំញ) ចំណែកខេត្តឯទៀត។ ដូចជា មាត់ជ្រូក ស្វាយទង ក្រមួនស ឡុងហោ ឡាំសីង តាន់សុនញឹក ជាដើម ស្ថិតនៅក្រោមអំណាចគ្រប់គ្រង ខ្មែរនៅឡើយទេ គឺថានៅក្រោមការគ្រប់គ្រងរដ្ឋអំណាច នៃស្តេចស៊ីហនុ ។ ខេត្តខ្មែរទាំងពីរ ដែលបារាំង ផ្ទេរឲ្យទៅយួននោះ ជាខេត្តខ្មែរធំៗ ជាងគេបង្អស់ ។

ដើម្បីឲ្យសង្គ្រាមរំដោះជាតិ រាលដាលមកលើប្រជារាស្រ្តខ្មែរ ពួកវៀតមិញ (យួនវ៉េ) នាំគ្នា យកភូមិខ្មែរ ជាជម្រក ជាទីតាំងមូលដ្ឋានទ័ព ។

ដើម្បីវាយបង្រ្កាបពួកវៀតមិញ អាណានិគមបារាំង សង់បន្ទាយនៅកណ្តាលភូមិខ្មែរ នៅតាមគ្រប់ឃុំខ្មែរ ។ បារាំងតាំងបន្ទាយទាហ៊ាន មួយយ៉ាងធំ នៅឡុងហោ ។ នៅពេលហាត់ហ្វឹនហ្វឺនម្តងៗ ពួកទាហ៊ានបារាំង ក្រោមឥទ្ធិពលនៃពួកអ្នកឲ្យការយួន នាំពួកបារាំងទៅហាត់បាញ់ នៅតាមព្រៃដែលខ្មែររសនៅ។ ខ្មែរអ្នកស្រុក ត្រូវរត់ចោលផ្ទះភូមិលំនៅឋាន ។

ដាទីបញ្ចប់ ខេត្ត មាត់ជ្រូក ខេត្តស្វាយទង ក្រមួនស ខេត្តឡុងហៃ ខេត្តឡាំសឹង ខេត្តតាន់សុនញឹក ក្លាយទៅជា ដាតំបន់ ប្រទាញប្រទង់ ពីព្រោះ ពួកយួនផង ហើយនិង បារាំង មកតាំងមូលដ្ឋានទ័ព នៅតំបន់នេះ ។

# ទាមទារឯករាជ្យ អំពីបារាំង

មេដឹកនាំខ្មែរ ដោយមានសម្តេចសង្ឃ ជួនណាត ហើយនិង សម្តេចប្រវនរតន៍ អ៊ុំវុត្ត ដាអាទិ៍ លោកតែងតែទទូច ដារឿយៗ ទូលស្តេចនរោត្តមស៊ីហានុ ថារដ្ឋកម្ពុជា យើងត្រូវការ ដាបន្ទាន់ កងទ័ពប្រជាយុទ្ធករ (Popular Forces) តាមគំរូ កងទ័ពវៀតមិញ ដើម្បី ការពារ មាតុភូមិយើង។ ប្រទេសជាតិខ្មែរត្រូវការ កម្លាំងទ័ពជាតិ ដើម្បីប្រចាំងទប់ទល់ និងនយោបាយ លេបទឹកដី ជិះជាន់ បរទេសយួនសៀម ហើយនិងទាមទារ ឯករាជ្យ អំពីអាណានិគមបារាំង។

ឧត្តមសេនីយ ស្ហាល ដឺហ្គោល (Charles De Gaulle) ក្នុងឆ្នាំ ១៩៤៧ បានធ្វើទស្សនៈ កិច្ច នៅកម្ពុជាក្រោម មកជួបពួក មេខ្មែរក្រោម ដែលបានធ្វើពលិ្លកម្ម បូជាជីវិត ជួយរំដោះ បារាំង អំពីការជិះជាន់ អាល្លឺម៉ាញណាស៊ី។ ឧត្តមសេនីយ ស្ហាល ដឺហ្គោល ថ្លែងអំណរ គុណ ចំពោះមេដឹកនាំខ្មែរក្រោម ដែលមាន តាណឹប, ពៅទ្យសេង ហើយនិង លោកគ្រូស៊ុំទ ជា តំណាង ។ រួចហើយ ដឺហ្គោល ទូន្មានមេដឹកនាំខ្មែរថា ប្រទេសខ្មែរ ត្រូវតែបង្កើត កងទ័ពជាតិ ខ្មែរមួយ យ៉ាងពូកែរ ដើម្បីការពារ ទឹកដីខ្មែរ ។ យួន គេរៀបចំ លេប ទឹកដីខ្មែរ អស់ហើយ នៅពេលខាងមុខនេះ ។

ប្រហែល មួយឆ្នាំក្រោយមក ស្ហាល ដឺហ្គោល ដោយមានការ ប្រេះចារ ក្នុងរង្វង់ គណៈបក្សរបស់គាត់។ ក៏សូមលាលែងឈប់ពីមុកតំណែង ។ រដ្ឋភិបាលបារាំង សង្គមនិយម គ្គីម៉ូឡេ (Socialist Government of Guy Mollet) ឡើងមកជំនួស ហើយសំរេច ក្នុង ឆ្នាំ ១៩៤៩ ផ្ទេរអំណាចគ្រប់គ្រង ខេត្តកម្ពុជាក្រោមពីរ គឺខេត្តព្រះត្រពាំង ហើយនិងខេត្តព្រះលាវ

ឲ្យទៅយួន ។ ខេត្តមាត់ជ្រូក ខេត្តស្វាយទង ក្រមួនស ឡុងហៃ ឡាំសីង តាន់សុនញឹក ស្ថិតនៅក្រោម អំណាចគ្រប់គ្រងខ្មែរ នៅក្រោមការគ្រប់គ្រងរដ្ឋអំណាច នៃស្តេច ស៊ីហនុ ។

# សម្តេចសង្ឃជួនណាត បង្កើតចលនាតស៊ូខ្មែរ

ក្រោយអំពីសង្គ្រាមលោកលើកទីពីមក អាណានិគមអង់គ្លេស ហើយនិងបារាំង ចុះអោនថយ ។ ប្រទេសនានា ដែលនៅក្រោមអាណានិគមនិយម នាំគ្នាក្រោកឈរ បះបោរ ទាមទារ ឯករាជ្យ រាងៗខ្លួន ។ ចិន ឥណ្ឌា អាហ្វ្រិកា នាំគ្នា វាយកំទិច អាណានិគមនិយម។

យួនកាន់ អាវុធ វាយបារាំង ។ ចំបាំង ដើម្បីឯករាជ្យនេះ រាលដាល គ្រប់ទិសទី ។ អាណានិគម វាយបង្រ្កាប វិញយ៉ាងសាហាវ ។ ទោះបីជាខ្មែរចង់ក៏ដោយ ឬមិនចង់ក៏ដោយ ក៏សង្គ្រាមរំដោះជាតិ មុកតែ រាលដាល មកដល់ ប្រទេសខ្មែរដែរ ។

ដោយឃើញយួន វាយបារាំង សម្តេចសង្ឃ ជួនណាត ហើយនិងមេដឹកនាំខ្មែរក្រោម យល់ឃើញថា ខ្មែរយើងត្រូវតែ ក្រោកឈរ វាយ បារាំងជាមួយ ចលនាពិភពលោក ដែលបះបោរ ទាមទារឯករាជ្យ។ បើមិនដូច្នេះទេ ដល់ពេលយួនឈ្នះ មុកតែយួនលេបទឹកដីខ្មែរហើយ។

ដោយហេតុតែ យួនយកភូមិខ្មែរ ជាជម្រកទ័ព ជាហេតុបណ្តាលឲ្យបារាំង ដុតភូមិខ្មែរ ទាត់ធាក់អ្នកភូមិខ្មែរឥតមានត្រាប្រណី។ អ៊ីវទួត ត្រូវ បារាំងចាប់យក ទៅទាត់ បាក់ធ្មេញដុំនិបី ។ អ៊ីវទួត លួចរត់ចេញពីគុកបារាំង រួច ហើយគាត់ដូរឈ្មោះ ដាក់ជា អ៊ីវទួត ។ ដើម្បី គេចអំពី បារាំងចាប់ចង គាត់ចូលសាងផ្នួស ។ តាស៊ុទជាមេដឹកនាំ ខ្មែរក្រោមដែល រាស្ត្រ ចូលចិត្ត ហើយដែលធ្វើជា ទាហ៊ានបារាំង ទៅច្បាំងនៅអាល្លឺម៉ាញ ក្នុងជួរកងទ័ព បារាំង ។

យួនតែងតែ ព្យាបាទ ចាក់រុក តាមសម្លាប់ចោល មេដឹកនាំខ្មែរពូកែរ ឧទាហរណ៏ ដូចជា តាស៊ុទ ។ យួនចាក់រុក ប្រាប់បារាំងថា តាស៊ុទ ជាមេខ្មែរបដិវត្ត ។ ដោយជឿ តាមពាក្យចោទនៃយួន ទាហ៊ានបារាំង ចាប់តាស៊ុទទៅទាត់ សន្លប់បាត់ស្មារតី សឹងតែ រាល់ថ្ងៃ ។

ថ្ងៃមួយ តាស៊ិទ លួចយកកាំភ្លើងយន្តបារាំងបាន គាត់រត់ ចូលព្រៃ ទៅបង្កើត ចលនាឥស្សរៈ។ ពីរឆ្នាំក្រោយមក យួនសម្លាប់ តាស៊ិទចោល ។

សម្តេចសង្ឃជួនណាត សម្តេចប្រវ៉ែនរតន៏អ៊ុំទ្ធួត តាណឹប ពេទ្យសេង តាស៊ិទ ហើយ និង តាសុខ (តាសុខ ត្រូវជាប្អូន តាស៊ិទ) ហើយនិងមេដឹកនាំខ្មែរឯទៀត យល់ឃើញថា បើ យើងពឹងផ្អែកលើយួន សូមឲ្យកងទ័ពយួនច្បាំងរំដោះ ប្រទេសខ្មែរ ជុំនួសខ្មែរ មានន័យថាយើង ពឹងយួន ឲ្យយួនស្លាប់ ជុំនួសខ្មែរ ដើម្បីឯករាជ្យខ្មែរ -នៅថ្ងៃក្រោយនៅពេលដែលវៀតណាម ឈ្នះសង្គ្រាម ពួកវៀតណាម មុកតែ មិនដើរចេញអំពីស្រុកខ្មែរទេ ។ យួនគេនិងកាន់កាប់ ស្រុកខ្មែរ ហើយ លេបទឹកដីខ្មែរ ជាមិនខានឡើយ ។ ហេតុដូច្នេះហើយ បានជាសម្តេចសង្ឃ ជួនណាត ហើយនិង សម្តេចប្រវ៉ែនរតន៏អ៊ុំទ្ធួត ព្រមទាំង មេដឹកនាំខ្មែរ ឯទៀត សម្រេចចិត្ត បង្កើតចលនាតស៊ូរខ្មែរ រំដោះខ្មែរកម្ពុជាក្រោម ។

លោកគ្រូមហាសុខ ដែលជាសច្ចាំង តាដុងភ្នំគូលែន លោកមានប្រសាសថា ÷ យើងត្រូវ បង្កើតចលនាបី ទន្ទឹមគ្នា ឯករាជ្យអំពីគ្នា ក៏ប៉ុន្តែជាប់គ្នា ជាក្បាល ជាកន្ទុយ ក្បាលចូល កន្ទុយចេញ ឬ ក្បាលចេញ កន្ទុយចូល មួយនៅក្នុង មួយនៅក្រៅ មួយនៅជា មួយយួន ។ ចលនាទីមួយ បង្កប់ខ្លួននៅជាមួយរាជរដ្ឋាភិបាល ចលនាទី២ បង្កប់ខ្លួនជាមួយ ពួកយួនវៀតម៉ិញ ចលនាទី៣ គឺចលនាខ្មែរឥស្សរៈ ។

ខ្មែរត្រូវតែមានគ្នាយើង ចូលបង្កប់ក្នុងចលនាឯទៀត។ ដើម្បីទីមួយ សឹក្សាយុទ្ធ សាស្ត្រ យួនវៀតម៉ិញវៀតកុង ហើយនិង ដឹងនូវនយោបាយ អាទិ៍កំបាំង នៃចលនាឯទៀត ជាពិសេស ពួកវៀតម៉ិញវៀតកុង ។ ចលនាដែលចូលទៅ បង្កប់ខ្លួនជាមួយ យួន គឺចលនាក្អែកខ្មៅ ។

ឆ្នាំ ១៩៥៦ គណៈសង្ឃ តាមការស្នើរនៃ សម្តេចប្រវ៉ែនរតន៏ អ៊ុំទ្ធួត បានចាត់ខ្ញុំ ឲ្យ ចូល ជាមួយពួក វៀតម៉ិញវៀតកុង តាមរយៈនៃពួក ស៊ីអៃអេ អាមេរិកាំង ។ ខ្ញុំទទួលការ ហ្វឹកហ្វឺនអំពី ស៊ីអៃអេ ជាកងពិសេស (Special Force) ។ រួចហើយ ខ្ញុំចូលជាមួយ វៀតកុង

។ ក្នុងចំណោមបេក្ខជនចំនួន ១៦០០ នាក់ ពួក ស៊ីអៃអេ ជ្រើសរើសយកបានតែ ៤០ នាក់ យកមក ហ្វឹកហ្វឺនបង្ហាត់ រួចបញ្ជូនខ្លួន ឲ្យចូលបង្កប់ខ្លួន ក្នុងជួរកងទ័ពយួនហាណូយ ។

ពួកវៀតមិញ វៀតកង ក្រោយពីហ្វឹកហ្វឺនបង្ហាត់ពួក ៤០ នាក់នេះ តាមក្បួនយុទ្ធសាស្ត្រ យួនកុម្មុយនិស្ត រួចហើយ ចាត់តាំង ពួក ៤០នាក់នេះ ឲ្យបញ្ជាទ័ព វាយ ពួកទាហ៊ានយួន ខាងត្បូង ។ ខ្ញុំបានឡើងជា ពីមេក្រុម រហូត ជា មេបញ្ជាកងវរៈសេនា វៀតកង (Battalion commander) ។

ជប់ប្រាំឆ្នាំក្រោយមក ក្នុងចំណោម ៤០ នាក់ នេះ ៤ នាក់នៅរស់ ។ ៣៦ នាក់ស្លាប់ ដោយពួកយួន កុម្មុយនិស្តវៀតកង សម្លាប់ចោល ឬស្លាប់ដោយចំបាំង ។ ភារៈកិច្ចនៃពួក ៤០នាក់នេះ គឺ រៀនសូត សង្គ្រាមវាយច្នក់ របៀបយួនកុម្មុយនិស្ត ហើយនិងស៊ើបអង្កេតការ អំពីយុទ្ធសាស្ត្រយួនកុម្មុយនិស្ត ស៊ើបពីខាងក្នុងទៅក្រៅ ស៊ើបពួកយួនកុម្មុយនិស្ត ដើម្បីឲ្យដឹងច្បាស់ថា មេទ័ពយួនខាងត្បូងណាមួយ ដែល ចូលដៃ ធ្វើការឲ្យ ពួកយួនកុម្មុយនិស្ត ។ ពួកស៊ីអៃអេ សម្លាប់ចោលទាំងអស់ ពួកមេទ័ពយួនខាងត្បូង ដែល មានក្បាលពីរ ។

សម្តេចអ៊ីវ៉ូត ជាអ្នកគូរ (Logo) រូបក្បាល ដំរី ជាបាផច្ចនា សំរាប់សំគាល់ ចលនាខ្មែរឥស្សរៈ ។ លុះដល់ថ្ងៃក្រោយមក គណបក្សប្រជាធិបតេយ្យ ហើយស៊ីងម៉ុកថាញ់ បានយកសញ្ញា ក្បាលដំរីនេះ ជាបាផច្ចនា មកប្រើ សំរាប់ តំណាង ចលនារៀងៗខ្លួន ។ ហើយសម្តេចអ៊ីវ៉ូត ជាអ្នក ឲ្យឈ្មោះចលនា ដែលបង្កប់ខ្លួនចូលក្នុង វៀតមិញវៀតកង ជាចលនាក្អែកខ្មៅ ដោយយកតាមគោលគំនិត (Black Eagle) ។

## ចៅដារា ~ អគ្គមេបញ្ជា កន្សែងស ក្អែកខ្មៅ

# វេរ្យកាលស្ដេចស៊ីហនុ (ភាគទី ៣)

## យួនខ្ញុំដៃស្ដេចសីហនុ សម្លាប់កងទ័ពស៊ីហនុនិយម

ដំណើររឿងដើម យួនខ្ញុំដៃស្ដេចសីហនុ សម្លាប់កងទ័ពស៊ីហនុនិយម មានដូចតទៅ÷

### កងជីវពល ហើយនិងនារីក្លាហាន

ឆ្នាំ ១៩៥៣ ស្ដេចស៊ីហនុ បានបង្កើតកងជីវពល និងនារីក្លាហាន បានមួយសែននាក់ ដើម្បី កំញើញវាយអាណានិគមបារាំង ។ ពួកវៀតមិញ បានបង្កប់ខ្លួនចូលក្នុង ចលនា កង ជីវពល និងនារីក្លាហាន បានយ៉ាងតិចណាស់ ៣៥ ភាគរយ ពីព្រោះ ពួកវៀតមិញ គេធ្លាប់ ប្រើស្មៀតនេះ ជាមួយបារាំង រួចម្ដងហើយ កាលពីឆ្នាំ ១៩៤៧-៥២ ។

### កងទ័ពខេមរភូមិន្ទ

**(FORCE ARMÉE ROYALE KHMÈRE, FARK)**

នៅពេលប្រទេសខ្មែរទទួលឯករាជ្យ នៅថ្ងៃ ៩ វិច្ឆិការ ឆ្នាំ ១៩៥៣ រដ្ឋភិបាលបារាំង ប្រគល់កងកម្លាំងទ័ព ទាហ៊ានជើងក្រហម គឺពួកទ័ពស្រួច (Regular forces) ហើយនិង ទាហ៊ានជើងខ្មៅ គឺពួកទ័ពស្វ័យត្រាន (Territorial forces) ឲ្យមករដ្ឋភិបាលខ្មែរ ។ ពួកយួន គេឥតចង់ឲ្យខ្មែរមានទ័ព ពូកែរទេ ដូច្នេះ ពួកវៀតណាម គេពន្យល់ស្ដេចស៊ីហនុ ឲ្យរំលាយ ទ័ពទាហ៊ាន ជើងក្រហម ចោលចេញ ទុកតែ ទ័ពទាហ៊ានជើងខ្មៅ ។ ដើម្បី បង្កើតកងទ័ព ខេមរៈភូមិន្ទ (Royal Armed Forces) មេទ័ពស្ដេចស៊ីហនុ ដកកាំភ្លើង អំពីកងទ័ពពូកែរ ពួកជើងក្រហម ហើយ យកពួក ពូកែរ ទៅចូល ជាមួយពួកមិនពូកែរ ។

អគ្គមេបញ្ជាការសឹក ស្ដេចស៊ីហនុបាន ដកហូត កាំភ្លើង (Garand M1) ចំនួន ៥,000 ដើម ពីពួកជើងក្រហម យកទៅកប់ទុកនៅភូមិលង្វែក សាលាលេខប្រាំ កំពង់ឆ្នាំង។

ក្រោយមក គេសង់ បន្ទាយទាហ៊ានមួយ នៅកន្លែងកប់កាំភ្លើងនោះ ដែលគេដាក់ឈ្មោះថា បន្ទាយលង្វែក ។

ពីរឆ្នាំក្រោយអំពីឯករាជ្យ ក្នុងឆ្នាំ ១៩៥៦ ស្តេចសីុហានុ សំរេចចិត្តបង្កើត កងស្វ័យត្រាន ដើម្បីការពារសន្តិសុខ ។ ការបង្កើតកងស្វ័យត្រាននេះ តម្រូវឲ្យ រដ្ឋភិបាលខ្មែរ ចែកកាំភ្លើង ឲ្យប្រជានុរាស្ត្រកាន់ ដើម្បីការពារភូមិ ។ យួនវៀតមិុញ បញ្ចូលគ្នាគេ ចូលកងស្វ័យត្រាន តាមភូមិឃុំ ដែលយួន កាន់កាប់ ។ យួនរៀបចំយ៉ាងត្រឹមត្រូវ តាមក្បួនខ្នាត ជាស្រេច ដើម្បីទទួលកាំភ្លើង ។

រឿងដដែលកើតមានឡើងជារឿយ។ ប្រសិនបើយើង យកចិត្តទុកដាក់ ពិនិត្យពិច័យ ។ អាណានិគមបារាំង ដើម្បីបង្ក្រាបយួនវៀតមិុញ បារាំងក៏បានបង្កើត កងស្វ័យត្រានដែរ ។ ដើម្បី បង្កើតកងស្វ័យត្រាន មេភូមិ និមួយ។ ត្រូវការ ប្រជាពលរដ្ឋណាដែល មានអត្តសញ្ញាណប័ណ្ណ ។ លុះត្រាតែមាន អត្តសញ្ញាណប័ណ្ណ ទើបមេភូមិ អាចប្រគល់កាំភ្លើង ឲ្យបាន ។ ខ្មែរយើង មិនសូវ មានកាត អត្តសញ្ញាណប័ណ្ណទេ ។ មេភូមិខ្មែរមិនសូវជួយ ដោះស្រាយ បណ្ហា អត្តសញ្ញាណប័ណ្ណ នេះជូនរាស្ត្រយើងទេ ។ ចំណែកឯ ពួកវៀតណាម វិញ គេចេះធ្វើ បញ្ជីក្រដាស់ស្នាមទាំងអស់នេះ។ នៅតាម ភូមិយួន មេភូមិក៏យួន ប្រជារាស្ត្រក៏យួន ។ មេភូមិយួន គេអាចធ្វើ ក្រដាស់ស្នាម កែរសំរួល សមស្រប ដាក់អ្នកភូមិ ដែលជាជនជាតិយួន ជាជាតិខ្មែរ តាមតែ សេចក្តីត្រូវការ របស់គេ ។ ហេតុដូច្នេះ កាលពីសម័យអាណានិគមបារាំង ពួកយួនវៀតមិុញ បង្កប់ខ្លួន ធ្វើជា កងស្វ័យត្រាន នៅពាស់ពេញតាមមូលដ្ឋាន វៀតណាម ក្នុងស្រុកខ្មែរ ។ ពួកយួន ទទួល កាំភ្លើងដែល បារាំងចែកឲ្យកងស្វ័យត្រាន បានយ៉ាងច្រើន ហើយយ៉ាងស្រួល ដើម្បីចាប់ផ្តើម បង្កើតចលនា តស៊ូ ប្រដាប់អាវុធ។

លុះដល់ ស្តេចសីុហានុ បង្កើតកងទ័ពស្វ័យត្រាន យួនវៀតមិុញ ប្រើយុទ្ធវិធីដដែល ដើម្បីទទួលកាំភ្លើង ពីស្តេចសីុហានុ ។ ជាទីបញ្ចប់ ស្តេចសីុហានុ ប្រគល់ កាំភ្លើងឲ្យ យួនវៀត

មិញកាន់ ។ ថ្ងៃក្រោយមក យួនប្រើ អាវុធនេះ ដើម្បីពង្រីកហើយ និងពង្រឹង ការ គ្រប់គ្រង យួន នៅក្នុង ប្រទេសខ្មែរ ។

រដ្ឋាភិបាល សម្ដេចសុីហានុ យកកាំភ្លើង (Garand M1) យ៉ាងល្អចំនួន ៥,០០០ ដែល កប់ទុកនៅ ភូមិលង្វែក យកទៅចែកឲ្យ ពួកកងជីវពលស្វ័យត្រាន ។ ពួកយួនវៀតមិញ នាំគ្នា រៀបចំជាកងជីវពលស្វ័យត្រានខ្មែរ មកទទួលកាំភ្លើងទាំងអស់នេះ ។ ជាទីបញ្ចប់ កាំភ្លើង (Garand M1) យ៉ាងល្អ ចំនួន ៣,០០០ ដើម ធ្លាក់ទៅលើដៃ ជៀងថៃសុីង, អុងចឺយ, ប៉ុលពត, ដាបឈួន, ដៀវសុឹង ក្នុងឆ្នាំ ១៩៥៦ ។ ពួកយួនវៀតមិញ យកអាវុធទាំង អស់នេះ មកបំពាក់ ឲ្យពួកខ្មែរវៀតមិញ ដែលមាន ដៀវសុឹង ដាបឈួន ហើយនិងប៉ុលពត ជាមេ ។ ដោយគ្មាន អ្នកណាចេះ យុទ្ធសាស្ត្រយោធា ទើប ដៀវសុឹង សំរេចចាត់តាំង ប៉ុលពត ឲ្យធ្វើ ជាមេ បញ្ជាការ នៃកងស្វ័យត្រាន ខ្មែរវៀតមិញ ៣០០០ នាក់នេះ ។

ការចាត់តាំង ប៉ុលពតជាអគ្គមេបញ្ជាការ នៃកងពល ៣០០០នាក់នេះ ជាកត្តាដ៏ សំខាន់មួយ ដែលរុញច្រាន ប៉ុលពត ឲ្យឡើង ធ្វើធំ កាន់តែ ធំឡើងៗ រហូត ក្លាយទៅជា មនុស្ស ទីមួយនៃ គណៈ បក្សខ្មែរក្រហម ។ សូមកត់សំគាល់ថា ម្ដាយសាឡុតស ជាជន ជាតិយួនវ៉ៃ ហើយឳពុកគាត់ ជាជន ជាតិចិន នៅភូមិបញ្ញាជី កំពង់ធំ ។ (ប្រភពពិតមាន ÷ ឧត្តមសេនីយ ដួងសំអុល)

កងទ័ពខេមរៈភូមិន្ទ (Force Armée Royale Khmère, FARK) នេះ ដោយបាន បុណ្យសក្តិ មានមុខមាត់ ថ្កុំថ្កើង ដោយសារ ស្ដេចសីហានុ មានចិត្តស្មោះត្រង់ ជាមួយស្ដេច សុីហានុ សុកចិត្តបូជាជីវិត ដើម្បីស្ដេច សុីហានុ ។ កងទ័ពខេមរៈភូមិន្ទនេះ មិនធ្វើរដ្ឋ ប្រហា ១៨ មីនា ១៩៧០ ទម្លាក់សម្ដេចសុីហានុទេ ហើយ ក្រោយពីរដ្ឋប្រហារមក កងទ័ពខេមរៈ ភូមិន្ទនេះ នៅតែគាំទ្រ ស្ដេចសុីហានុដដែល ហើយ លួចផ្ដល់អាវុធ គ្រាប់ ឲ្យកងទ័ព ម៉ាគី សុីហានុ នៅពេលដែល ស្ដេចសុីហានុ ប្រកាស់អំពាវនាវ សូមឲ្យប្រជានុរាស្រ ខ្មែរ ឲ្យរត់ចូល ព្រៃម៉ាគី ។ មាននាយ ទាហ៊ានខ្លះនាំទ័ព ទាំងកងវរៈសេនា (Battalion) រត់ចូលជាមួយស្ដេច

ស៊ីហនុ ។ វរៈសេនីឯក ចេងសុយ៉ុមប៊ិន ប្រុងប្រៀបនាំកងវរៈសេនាគាត់ (Battalion) រត់ចូលព្រៃ ចូលជា មួយស្តេចស៊ីហនុ ប៉ុន្តែគេដឹងការមុន គេចាប់គាត់ដាក់គុក ។

## ដាប ឈយន ជាយួនវៀតមិញបង្កប់ខ្លួន

ដាបឈួន, ថាប់ហ៊ីង, ស៊ីរីភេម, ឱុកដោ, ដាប់សោ, ដៀវង៉ឹង ជា មេវៀតមិញដែលមកបង្កប់ខ្លួនធ្វើជាខ្មែរឥស្សរៈ ។

ដៀវង៉ឹង ជា មិត្តភក្តិយ៉ាងជិតស្និទ្ធនៃដាបឈួន ហើយជាអគ្គមេបញ្ជាការ កងទ័ពខ្មែរវៀតមិញ នៅខេត្តបាត់ដំបង សៀមរាប កំពង់ធំ ។

នៅពេលដែល ដៀវង៉ឹងចាត់តាំង សាឡុតស (ប៉ុលពត) ឲ្យធ្វើជា អគ្គមេបញ្ជាការកងពល ប្រដាប់អាវុធ ៣០០០ នាក់ ទាបាញ់ (រដ្ឋមន្ត្រី ក្រសួងការពារជាតិ សព្វថ្ងៃនេះ) ជា ឈ្លប នាំផ្លូវ ។ ទាបាញ់ ជាជនជាតិ លាវកាត់យួន ។

នៅពេលនោះ វៀតមិញ បញ្ជូនគណៈ ប្រតិភូរ ដឹកនាំដោយ លាវកែវមុនី (ហៅកែវសារ៉ុ) មិត្តខ្លែង (គណៈតំបន់) ទៅ វាយលាវ សេរី ហើយនិង អាមេរិកាំង នៅ ប្រទេស លាវ នាចុងឆ្នាំ ១៩៥៧ ។ ទាបាញ់ ជាអ្នកនាំផ្លូវ គណៈប្រតិភូរនេះ ដើរពី កំពង់ធំ ទៅស្រុក លាវ ឆ្ពោះសំដៅទៅ ទីក្រុងវៀងច័ន្ទ។ ពួកគណៈ ប្រតិភូនេះ មានចំនួន រាប់រយ នាក់ នាំគ្នាទៅសំណាក់អាស្រ័យ នៅតាមវត្ត ដូចជា វត្តភូ វត្តថាតហ្លួង និងវត្តលាវ ឯទៀត។ យ៉ាងណែនប៉ែស ។ នៅពេលជាមួយគ្នានោះ អង្គការវៀតមិញបាន បញ្ជូនខ្ញុំឲ្យទៅ សិក្សាយុទ្ធសាស្ត្រ នៅខេត្ត សៀងខ្វាង ស្រុកលាវ ។ លាវកែវមុនី ហើយនិង តាខ្លែង ជាពួកក្អែកខ្មៅ ។

ឆ្នាំ ១៩៥៧ ហាណូយទើបតែ ស៊ីញ៉េ សន្ធិសញ្ញា ជាមួយអាមេរិកាំង ព្រមព្រាងគោរពអាព្យាក្រិត ហើយនិង បូរណភាពទឹកដី ប្រទេសលាវ ។ ហាណូយ ស៊ីញ៉េ សន្ធិសញ្ញានេះ ដើម្បីបោក មតិអន្តរជាតិ ជាពិសេស បោកមតិប្រជាជនអាមេរិកាំង ។ តាម សន្ធិសញ្ញា

នេះ អាមេរិកាំង ហើយនិង ហាណូយត្រូវដកទ័ពចេញ ពីស្រុកលាវ ។ អាមេរិកាំង គោរព កិច្ចសន្យា ដោយ សភាអាមេរិកាំង ដែលមាន លោក ហ្វុលប្រៃ (William Fulbright) គណៈបក្សប្រជាធិបតី ជាអ្នក ពិនិត្យប្រឹតប្រៀង យ៉ាងម៉ាត់ឲ្យាត់ជាទីបំផុត បង្ខំឲ្យកងទ័ព អាមេរិកាំងគោរព រីឯ ហាណូយ វិញ គ្មានគោរព ពាក្យសន្យាអ្វីសោះទេ ។ តាមការពិត ហាណូយដាក់ទ័ព បន្ថែម ចំនួន ២០,០០០ នាក់ ថែមទៀត ដើម្បី វាយ កំទិច វាលក្រឡ (Plaine des Jarres) ។

ហាណូយ កែនខ្មែរវៀតមិញ ពីស្រុកខ្មែរ រាប់ពាន់នាក់ យកទៅវាយ លាវសេរី ។ បើលាវសេរីចាញ់ លាវនិង ក្លាយទៅជាកុម្មុយនិស្ត ហើយនិងធ្លាក់ ទៅក្នុងកណ្ដាប់ដៃ យួនហាណូយ ។

នៅក្នុងពេលនោះ ឆ្នាំ ១៩៥៧ ស្ដេចសីហនុ ប្រកាស់ ជួយអង្ករ ចំនួន ៥០០ តោន ទៅលាវ ដើម្បីជួយជនភៀសខ្លួនលាវ ។ តាមការពិត ស្ដេចសីហនុ បំរើ នយោបាយ យួន ហាណូយ ។ ពីព្រោះ អង្ករជំនួយទៅលាវ នៃស្ដេចសីហនុនេះ សំរាប់ចិញ្ចឹម ពួកខ្មែរ វៀតមិញ រាប់ពាន់នាក់ ដែល ពួកយួនវៀតមិញ កែនយកមកវ៉ៃ លាវសេរី-អាមេរិកាំង នៅ វៀងច័ន្ទ ហើយនិង វាលក្រឡនេះឯង ។ ខ្ញុំជួប ហូជីមិញ នៅសៀងខ្វាង ជាថ្មីម្ដងទៀត នៅជិត វាលក្រឡ ។

ស្ដេចសីហនុ នៅពេល ទាមទារឯករាជ្យ ឆ្នាំ ១៩៥៣ លោកយាងទៅ ជ្រកក្រោម ម្លប់នៃ អ៊ុងថឺយ ដែលជាអ្នកដឹកនាំនយោបាយ ហើយនិង ស៊ឺង (ង៉ៀន ថៃ ស៊ឺង) អគ្គមេ បញ្ជាការ កងទ័ពយួន តាមរយៈ ដាបឈួន, ង៉ៀវហ៊ឺង ដែលដាក់ទ័ពរាយនៅ ភូមិត្បែង ភូមិប្រដាក ភូមិបង្កោង ភូមិវត្តត្រាច ភូមិតាចាំង បឹងដាបឈួន គឺ រីមីនទ់ ភ្នំគូលែន ។ លុះដល់ខ្មែរបានឯករាជ្យ ស្ដេចសីហនុ ជឿជាក់ថា លោកជំពាក់គុណ ពួកយួន ហាណូយ លោកសំរេច ចាត់តាំង ពួកខ្មែរវៀតមិញទាំងអស់នេះ ឲ្យកាន់ការធំៗ ក្នុង កងទ័ពជាតិ

បូលិសគិញ និង រដ្ឋបាល ។ យួនហាណូយ ប្រើមធ្យោបាយដ៏មានប្រសិទ្ធភាព នេះ រាល់តែដង ដើម្បី បង្កប់ពួកយួនហាណូយ ចូលក្នុង កងទ័ពខេមរៈភូមិន្ទ ប៉ូលីសគិញ ហើយនិង រដ្ឋបាលខ្មែរ ។

ចំពោះពួកខ្មែរឥស្សរៈ ដែលពួកយួនវៀតមិញ យលឃើញថា ជាអ្នកប្រចាំង ដាច់ខាត និងនយោបាយយួនលេបទឹកដីខ្មែរ ពួកឥស្សរៈទាំងអស់នេះត្រូវរងគ្រោះ ដោយយួនចាក់រុកមុសាមួលបង្កាច់ ធ្វើឲ្យ ស្តេចសីហនុ ជឿថាជាពួកក្បថ ។ ជាទីបញ្ចប់ ឬមួយ ពួកអ្នកជាតិនិយម ទាំងអស់នេះ បានបុណ្យស័ក្តិតូចតាច កំប៉ិកកំប៉ុក ឬមួយត្រូវយួន លួចសម្លាប់ចោល ។

អាស្រ័យហេតុនេះ ដាបឈួនត្រូវបាន ស្តេចសីហនុ តែងតាំងធ្វើជា អភិបាលខេត្ត សៀមរាប រួចមក រហូតធ្វើជា រដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ ។ ចំណែកឯ កៅតក់ ដែលជា មេឥស្សរៈ មានទ័ពច្រើនជាងដាបឈួនទៅទៀត ក៏ប៉ុន្តែ ជាអ្នកប្រចាំង ដាច់ខាតនិង ដាបឈួន ត្រូវ ស្តេចសីហនុ កៀសទម្លាក់ចោល មិនឲ្យបុណ្យស័ក្តិ មិនឲ្យធ្វើអ្វីទេ នៅពេលក្រោយឯករាជ្យ។

## ហាណូយប៉ុនប៉ងធ្វើឃាដស្តេចសីហនុ ក្នុងឆ្នាំ ១៩៧៨ ចំណែកឯ លោកលន់ណល់ ហាមឃាត់ជានិច្ច មិនឱ្យបះពាល់ជីវិតស្តេចសីហនុ

នៅឆ្នាំ ១៩៧២ នៅពេលសម្តេចសីហនុ យាងទៅ ព្រៃម៉ាគី (Marquis) ដើម្បី ដឹកនាំកងទ័ព យួនហាណូយកុម្មុយនិស្ត មកវ៉ៃកំទិចកងទ័ពលោក លន់ណល់ សម្តេចសីហនុ យាងត្រឡប់ មក គង់នៅ កន្លែងដដែល នៅភូមិត្បែង ហើយនិងភូមិ គី រីមីនន់ ភូមិពីងជ័ត្រ ខេត្តសៀមរាប ។ សម្តេចយាង អំពីហាណូយមកទីក្រុងវិញ តាមរថភ្លើងយួន រួចចូល ប្រទេសខ្មែរ តាមស្ទឹងត្រែង សៀងប៉ាង ។ លោកឧស្សាហ៍កំសាន្ត ទឹកជាមួយអ្នកម្នាងនៅ ជ្រោះទឹកធ្លាក់ អូរយ៉ាដា សៀមប៉ាង រតនគីរី ។ មកដល់ សៀមរាប លោកសព្វព្រះរាជ ហឬទ័យ កំសាន្តទឹកនៅតាម ជន្លងជ្រោះភ្នំគូលែន។ ខ្ញុំ ហើយក្រុមខ្ញុំក្អែកខ្មៅ ប្រាំនាក់ នៅលាយឡំ ជាមួយពួកអង្គរក្ស ការពារស្តេចសីហនុ ដើរតាមស្តេចសីហនុ តាំងតែ ពិសៀម

ចាំង រហូត មកដល់ភ្នំគូលែន។ ពួកស៊ីអៃអេ បញ្ជាឲ្យបាញ់ស៊ីហានុចោល ។ លោកលន់ណល់ បញ្ជាផ្ទាល់ពួក យើងខ្ញុំ ថា ខ្មែរយើងមិនត្រូវបះពាល់ ជីវិតស្តេចស៊ីហានុទេ ។ បើយើង នាំគ្នាសម្លាប់អ្នកចេះដឹង ស្រុកខ្មែរយើង មុកតែហិនហោចហើយ នៅថ្ងៃមុខ។ ទុកជាស្តេចស៊ីហានុ លោកសងសឹកគំគួន ពួកយើងយ៉ាងណាក៏ដោយ យើងមិនត្រូវសម្លាប់អ្នកចេះដឹងទេ ។ ពួកយើងខ្ញុំ ទាំង ៥ នាក់សុទ្ធតែ ជាអ្នកកាំភ្លើងដៃឯក បាញ់ ៥០០ ម៉ែត្រ ឥតខុសទេ ។ បើលោក ប្រធានាធិបតី បញ្ជាឲ្យ ពួកយើងខ្ញុំធ្វើឃាដ ស្តេចស៊ីហានុ ពួកខ្ញុំទាំងប្រាំនាក់ អាចអនុវត្តិ បានយ៉ាងស្រួល ។

ពួកយួនហាណូយ យលឃើញថា ស្តេចស៊ីហានុ មានឥទ្ធិពលខ្លាំងណាស់ ។ ស្តេចស៊ីហានុ អាចជួយបក្សណាមួយដែល ខ្សោយអោនថយ ឲ្យឈ្នះបាន បើលោកចូលដៃកាន់ជើងបក្សនោះ ។ លោកចូលជាមួយពួកខ្មែរក្រហម ពួកខ្មែរក្រហមឈ្នះ ។ ស្តេចស៊ីហានុ ចូលជាមួយ យួនហាណូយ យួនហាណូយឈ្នះ ។ បើស្តេចស៊ីហានុ អត់ចូលជាមួយ ខ្មែរក្រហមទេ ទ័ពខ្មែរក្រហម វាយទ័ពលោកលន់ណល់ មិនឈ្នះទេ ។ បើស្តេចស៊ីហានុ អត់ចូលជាមួយ ខ្មែរក្រហមទេ ទាហ៊ានលោក លន់ណល់ ក៏មិនដាក់អាវុធទាំងអស់គ្នាទេ ។ ដោយសារតែ ស្តេចស៊ីហានុ ចូលជាមួយពួក ខ្មែរក្រហម បានជាពួកទាហ៊ានលន់ណល់ យល់ច្រឡំ នាំគ្នាដាក់អាវុធ ។ បើទាហ៊ានលោកលន់ណល់ មិនដាក់អាវុធ ទាំងអស់គ្នា ម្ល៉េះសម ពួកខ្មែរក្រហម មិនហ៊ាន សម្លាប់យ៉ាងវង្កាលដច្នេះទេ ពីព្រោះ អ្នកមិនដាក់អាវុធ អាចបង្កើតជម្រក ហើយរាស្ត្រប្រជា អាចរត់ទៅលាក់ខ្លួន ពួនបាន ។ ស្តេចស៊ីហានុ ទទួលខុសត្រូវ ចំពោះប្រវត្តិសាស្ត្រខ្មែរ ។

អាស្រ័យហេតុនេះ យួនហាណូយ សំរេចចិត្ត សម្លាប់ស្តេចស៊ីហានុ ដើម្បីចៀសវាង មិនឲ្យស្តេចស៊ីហានុធ្លាក់ទៅ ក្នុងដៃ ខ្មែរ ក្រហម ។

ថ្ងៃ ២៥ ធ្នូ ១៩៧៨ (Christmas Day) កងទ័ពហាណូយចំនួន ២០០,០០០ នាក់ វាយលុកប្រទេសខ្មែរ។ ហាណូយបញ្ជូន អ្នកឯកទេសយួន ខាងសម្លាប់ ១២ នាក់ មកសម្លាប់

ស្តេចសីហនុ នៅភ្នំពេញ ។ មួយអាទិត្យ មុន ក្រុមឃាដករឯកទេសយួននេះមក ដល់ភ្នំពេញ អៀងសារី ជន្លៀសស្តេច សីហនុ យកចេញ ទៅបាត់មុនទៅ រួចទៅច្លងទៅប្រទេសសៀម ធ្វើដំណើរឆ្ពោះ ទៅប៉េកាំង ។ ពួកឃាដករ យួននេះ វាខំដើររក ស្តេចសីហនុ គ្រប់ទិសទីរ ពីព្រោះ បទបញ្ជារបស់ ពួកវា គឺថា បើពួកវា សម្លាប់ ស្តេចសីហនុ មិនបានទេ ពួកវាទាំង ១២ នាក់នេះ មុកតែត្រូវ ក្រុមមួយទៀត មកសម្លាប់ពួកវាចោលមិនខានឡើយ ។ ដូច្នេះ ដើម្បីរស ពួកវាត្រូវរក ស្តេចសីហនុ ឲ្យឃើញ ។ ដល់ពួកយួនឃាដករនេះ ដឹងថា ស្តេច សីហនុ យាងទៅដល់ស្រុកសៀមហើយ អ្នកបកប្រែភាសាយួនខ្មែរ ដែលមកជាមួយ ពួកឃាដករ យួនទាំង ១២ នាក់នេះ រត់ចូលជ្រុំភៀសខ្លួនថៃ សូមចូលជ្រកកោន ប្រទេស អាមេរិកាំង ។ យួនអ្នកបកប្រែភាសា ចូលសារភាពចុះចូល អ្នកអគ្គការទូតអាមេរិកាំង និយាយ រឿងរ៉ាវទាំង អស់ ប្រាប់រដ្ឋទូតអាមេរិកាំង ។ ពួកឃាដករយួន ១២ នាក់ រសនៅ សព្វថ្ងៃនេះ នៅភ្នំពេញ យ៉ាងសុខ ក្សេមក្សាន្ត សប្បាយមានកិត្តយសខ្ពង់ខ្ពស់ ។ ខ្មែរដែល ជាអ្នក បើកបររថយន្ត នាំផ្លូវ មកសម្លាប់ស្តេចសីហនុ បានវង្វាន់ថានន្តរៈស័ក្តិ ឧត្តមសេនីត្រី បក្សជន គនបក្សប្រជាជន ។ ឥឡូវនេះ អ្នកបររថយន្តនេះ ជាអ្នកមានម្នាក់នៅភ្នំពេញ ។

ក្នុងឆ្នាំ ១៩៧៩ នៅពេលយួន កាន់ក្តាប់រដ្ឋអំណាច កម្ពុជាកណ្តាល ដៀវង៉ឺង ដែល តែងតាំងប៉ុលពត ឲ្យកាន់ទ័ព គាត់ងងឹតភ្នែក ។ យួនទម្លាក់បុណ្យស័ក្ត គាត់ ទុកគាត់ជា មនុស្ស គ្មានភារៈកិច្ច ។ ដល់គាត់ អស់បុណ្យទៅ នៅពេលយួនកាន់កាប់រដ្ឋ អំណាចខ្មែរ ដៀវង៉ឺង សូម្បី តែផ្ទះ របស់គាត់តាំងតែ ពីជំនាន់ របបសេរី គាត់ មិនអាចយកផ្ទះនេះ មកដាក់ ជាកម្មសិទ្ធរបស់គាត់ បានផងទេ ។

ជាមេរៀន យើងយល់ឃើញថា ជាទូទៅ យួនកុម្មុយនិស្ត ប្រើខ្មែរ ហើយខ្មែរវៀតមិញ តែមួយរយៈពេលទេ រួចទៅ យួនទម្លាក់ ចោលហើយ ។ យួនលើកឲ្យធ្វើធំ តែមួយរយៈពេលដ៏ខ្លី

ប្រសិនបើខ្មែរនោះ ពូកែរ ធ្វើការ មែន ។ ក៏ប៉ុន្តែ មិនយូរប៉ុន្មានទេ នៅទីបញ្ចប់ យួន មុខតែដកខ្មែរនោះចេញ ។ បើខ្មែរនោះ មាន ប្រជាប្រិយភាពខ្លាំង យួននឹងយក ទៅសម្លាប់ចោល។

បើខ្មែរនោះ ពូកែរខាងកាប់ សម្លាប់ ខ្មែរស្លូតត្រង់ ពេលនោះ យួនចាត់តាំង ឲ្យធ្វើធំ តទៅទៀត ដូចជាពួក អភិបាលខេត្ត នៃរដ្ឋភិបាល ហ៊ុនសែនសព្វថ្ងៃនេះ ។ ពួកចៅហ្វាយខេត្ត នៃពួកហ៊ុនសែន សុទ្ធតែពូកែរ សម្លាប់ ខ្មែរស្លូតត្រង់ទាំងអស់ សម្លាប់ខ្មែររាប់ពាន់នាក់ ដូចជា ចៅហ្វាយក្រុង ជុតមា, ណាំ ទំ, អ៊ុងសាមី ជាដើម ។ សម្លាប់កាន់តែច្រើនឡើង រឹតតែធ្វើធំឡើង ហើយ មិនចាំបាច់រៀនសូត ឲ្យចេះទេ ។

## ពាក្យខ្មែរវៀតមិញលប់បាត់ទៅ វាលេចចេញពាក្យខ្មែរក្រហម

យើងគួរតែពិចារណា ឲ្យបានល្អិតល្អន់ ។ ពីដើម ដើម្បី បញ្ជាក់អំពីពួក ចលនាតស៊ូ គេប្រើយ៉ាងរត់មាត់  ពាក្យតែពីរគត់ គឺពាក្យ ឥស្សរៈ ឬ ខ្មែរវៀតមិញ ។ ដល់ក្រោយមក ពាក្យខាងលើនេះបាត់អស់រលីង វាចេញពាក្យថ្មីមួយមក គឺពាក្យខ្មែរក្រហម ។ យើងចោទសួរ ថា តើពួកខ្មែរវៀតមិញ ឬវៀតមិញ មនុស្សទាំងអស់នេះ វាទៅណាអស់ហើយ ? ពួកទាំងអស់នេះ នៅរស់ទេតើ ហើយវាអត់ហោះហើរទៅណាទេ ! ពួកទាំងអស់នេះ វារស់ យ៉ាង ស្រួលនៅស្រុកខ្មែរ វាត្រូតខ្មែរ វាអត់ទៅស្រុកយួនទេ ក៏ប៉ុន្តែវាដាក់ឈ្មោះថ្មី ទៅជាពួក ខ្មែរក្រហម ។ បណ្តាញវៀតមិញ នៅចាក់ឫសគល់ នៅស្រុកខ្មែរជាយូរលុង មកហើយ ។ វាអត់ត្រឡប់ទៅ ស្រុកយួនវិញទេ! ពួកយួនវៀតមិញមានដី ឯណានៅ? មានត្រីឯណា ទទួលទានស្រួលដូច នៅស្រុកខ្មែរ?  ដូច្នេះ វាច្បាស់ណាស់ទៅហើយ ពួកវៀតមិញនេះវាអត់ ចេញអំពីស្រុកខ្មែរទេ ! ទោះបីមាន សន្ធិសញ្ញាស្ហឺណែវ ១៩៥៤ ឬ សន្ធិសញ្ញាអន្តរជាតិ ទីក្រុង ប៉ារីស ១៩៩១ បង្គាប់ឲ្យ យួនដកទ័ពចេញ អំពីស្រុកខ្មែរយ៉ាងណាក៏ដោយ ក៏យួនវៀត មិញ នៅចាក់ឫស នៅស្រុកខ្មែរដដែល តាំងភូមិ តាំងទីតាំង មូលដ្ឋានទ័ពវា នៅដដែល ។

នេះជាសេចក្តីសន្និដ្ឋាន យើងចង់បង្អួលបង្ហាញថា ពួកយួន វៀតមិញ បង្កប់ខ្លួនជាច្រើន នៅក្នុងជួរខ្មែរ ក្រហមនេះ ។ ហើយដោយហេតុតែ ពួកយួននេះ សុទ្ធសឹងជាអ្នកចេះដឹង ពួកនេះកាន់ ការណ៍ធំៗ ណាស់នៅក្នុងអង្គការខ្មែរក្រហម ។ ពួកគណៈដំបន់ ពួកគណៈភូមិភាគ ជាច្រើន ជាយួន បង្កប់ខ្លួន ធ្វើការក្រោម បញ្ជាហាណូយ ។

ក្រោយអំពី ជ័យជំនះខ្មែរក្រហម ១៧ មេសា ១៩៧៥ ប្រហែលមួយខែ ជនជាតិបរទេស ប្រហែល ១០០០ នាក់ ដែលរត់មកជ្រក នៅស្ថានទូតបារាំង ហើយនិងសណ្ឋាគាររ៉ូយ៉ាល នៅភ្នំពេញ ត្រូវខ្មែរ ក្រហម បញ្ជូនទៅប្រទេសថៃ តាមក្បួនរថយន្ត ។ មិត្តបែតជាមេបញ្ជាភូមិភាគ ផ្នែកសន្តិសុខ ប្រចាំស្ពាយដូនកែវ-បាត់ដំបង ។ ខ្មែរក្រហម ចាត់តាំងខ្ញុំឲ្យទទួលបន្ទុកខាង ដឹកជញ្ជូន ហើយនិង សំណង់ ។ ដោយហេតុតែស្ពានស្ពាយដូនកែវដាច់ក្បួនរថយន្តដឹកជនបរទេស ត្រូវឈប់ផ្អាក នៅស្ពាននេះ ។ ខ្ញុំជាអ្នកជួសជុល ស្ពានស្ពាយដូនកែវនេះ ។ នៅពេលដែលខ្ញុំ ដើរចូលព្រៃ ទៅរកកាប់ ឈើយកមកជួសជុល ធ្វើស្ពាននេះ ខ្ញុំឮពួក មិត្តបែត និយាយគ្នា ថាវា យកពួក អាមេរិកាំង យកទៅសម្លាប់ នៅជីតនោះ ។ ក្នុងចំណោម ជនបរទេស ប្រហែល ១,០០០ នាក់នេះ ពួកអាបែត វាដាក់គ្នា លួចស្តាប់ពយកជនបរទេសនេះ និយាយគ្នា ។ តាមសូរសៀង ភាសារ មិត្តបែតសំរេច ថាអ្នកនេះមួយជាជនជាតិអាមេរិកាំង ឬមិនមែន ។ រួចហើយ ពួកមិត្តបែត សម្លាប់ចោលទាំងអស់អ្នកណាមួយ ដែលវា យលថា ជាពួក អាមេរិកាំង ។

សំនួរ ÷ ហេតុអ្វី ក៏មិត្តបែតសម្លាប់ តែ ពួកអាមេរិកាំង ?

យើង អាចឆ្លើយបានថា÷ គឺមិត្តបែតចង់ឲ្យ ពិភពលោក ស្អប់ខ្ពើមខ្មែរ ។ ខ្មែរអាចឆ្កួតល្ងើលីលា សម្លាប់តែខ្មែរគ្នាឯង ប្រហែលជាគ្មាន អ្នកណាមួយ ភ្ញាក់ផ្អើលឈឺក្បាល វឹលមុខជាមួយខ្មែរទេ ។ ក៏ប៉ុន្តែ សម្លាប់ ជនបរទេស ជាពិសេស អាមេរិកាំង ជារឿងមួយទៀត ! មិត្តបែត សម្លាប់ពួកអាមេរិកាំង គឺនៅក្នុងគោល បំណងតែមួយគត់ គឺចង់ឲ្យ មតិអន្តរជាតិស្អប់ខ្ពើមប្រទេសខ្មែរ កុំឲ្យមានអ្នកណា យកភ្នែកមកមើលខ្មែរទៀត ។

ប្រាំមួយខែក្រោយមក មិត្តបែតចង់ យកខ្ញុំទៅសម្លាប់ចោល ។ ខ្ញុំប្រុងប្រៀបខ្លួនជានិច្ច ការពារជីវិតខ្ញុំ ហើយនិងគ្រួសារខ្ញុំ ដោយអាវុធ ។ ពូជពង្សខ្ញុំ ជាពូជគុណនិយម ។ ជិតាខ្ញុំ ឪពុកខ្ញុំ បងប្អូនខ្ញុំ ហើយនិង ខ្លួនខ្ញុំ ជាគ្រូគុណ ។ ថ្ងៃស្អែក ជាថ្ងៃដែល ពួកមិត្តបែត ចាប់ខ្ញុំ យកទៅសម្លាប់ចោល ។ យប់មុនថ្ងៃស្អែក នួនជា ចាប់មិត្តបែត ព្រមទាំងខ្សែរយៈវាទាំងអស់ ទៅសម្លាប់ចោល ទាំងអស់បាត់ទៅ ។ មិត្តបែត ជាយួនវៀតមិញ សម្លាប់សម្លាប់ អ្នកស្រុក ទាំងដំបន់ៗ ។ មិត្តបែត ពិមុន កាលពីសម័យសង្គម រសនៅស្រុកកន្ទី ស្រុកបាត់ដំបង ។

## នយោបាយអាមេរិកាំង ដើម្បីដោះស្រាយ បណ្ហាខ្មែរ ឆ្នាំ ១៩៧២ មុនពេលអាមេរិកាំង ដកទ័ពថយ ចេញអំពី ឥណ្ឌូចិន

រដ្ឋាភិបាលអាមេរិកាំង ដឹងច្បាស់ថា កងទ័ពលោកលន់ណល់ ចំនួន ពីរភាគបី លែង ច្បាំង ខ្មែរក្រហម ហើយបែរទៅជា សូមចុះចូលស្តេចសីហនុ ទៅវិញ ហើយនាំគ្នាប្រកាន់ ហើយនិង ផ្សប់ផ្សាយ សន្តិភាពនិយម ។ នៅវៀតណាមក៏ដូចគ្នាដែរ កងទ័ពយួនសេរី ងៀងវាន់ធីវ ភាគច្រើន លែងច្បាំង ពីពួកកុម្មុយនិស្ត ហើយសុទ្ធតែ សន្តិភាពនិយមដូចគ្នា ។ នៅកម្ពុជាកណ្តាល មានតែពួកខ្មែរក្រោម ពួកកន្សែងសទេ ដែលវាយយួនកុម្មុយនិស្តហា ណូយ ចំណែកឯ កងទ័ពខ្មែរឯទៀត ស៊ីហានុនិយម អស់ទៅហើយ ។ នៅវៀតណាមខាងត្បូង ក៏ដូចគ្នា ទ័ពយួន សេរី លែងវាយ យួនហាណូយ  មានតែកងទ័ពខ្មែរកម្ពុជាក្រោម ដែលនៅ ក្រោមបញ្ជាការផ្ទាល់អាមេរិកាំង ដែលវាយទ័ពយួនហាណូយ ចំណែកទ័ពយួនសេរីឯទៀតៗ លែងច្បាំង យួន កុម្មុយនិស្តហាណូយ ហើយសុទ្ធតែ សន្តិភាពនិយមទាំងអស់គ្នា ។ ទ័ពដែល វាយយួននៅ យួនខាងត្បូង សុទ្ធសឹងស្នាដៃ ខ្មែរក្រោម ទាំងអស់ ។ រួមសេចក្តីទៅ នៅកម្ពុជា កណ្តាល ក៏ពួកខ្មែរក្រោម ជាអ្នកច្បាំង ហើយនៅស្រុក យួនខាងត្បូងទៀត ក៏ខ្មែរក្រោម ជាអ្នកច្បាំង។ គិតទៅ ឃើញថាខ្មែរក្រោមទទួលទម្ងន់ចម្បាំង ដ៏ធ្ងន់មហិមា ។ ខ្មែរក្រោម ស្លាប់យ៉ាងវង្គាល នៅកម្ពុជាក្រោម ក៏ដូចកម្ពុជាកណ្តាល ។ ក៏ប៉ុន្តែ យើងនៅតែយលថា

សន្តិភាព សម្លាប់ខ្មែរ យើង រឹតតែខ្លាំងជាង ចម្បាំងទៅទៀត។ រសដោយ កាន់អាវុធ តតាំងនិងសត្រូវ វាគ្រាន់ បើជាង ទុកឲ្យសត្រូវចាប់យើងចង ហើយសត្រូវ សម្លាប់ យើង ស្រេចតែចិត្តវា ។

ខ្មែរក្រោមក្រោកឈរ ការពារសិទ្ធសេរីភាពខ្មែរ ។ ខ្មែរក្រោមអាចរំដោះយកកម្ពុជាក្រោម ពីរដង÷ លើកទី ១ នៅឆ្នាំ ១៩៦៤ នៅពេលទម្លាក់ ង៉ោឌិនយៀម ហើយនិង លើកទី២ នៅពេលដែល ខ្មែរយើង រៀបចំទម្លាក់ ប្រធានាធីបតី ង្វៀងវ៉ាន់ធីវ នៅពេលដែល ង៉ោឌីនយៀម ហើយនិង ង្វៀងវ៉ាន់ធីវ ធ្វើបាបខ្មែរក្រោម ។ អាមេរិកាំង លួងលោមបញ្ឆោតខ្មែរយើង សន្យានិងជួយខ្មែរ ក្រោម ឲ្យលុយ ដើម្បីកសាងស្រុកយើង នៅពេលក្រោយ ។ អាមេរិកាំង សូមកុំឲ្យ ខ្មែរក្រោម វាយទម្លាក់ ង្វៀងវ៉ាន់ធីវ នៅពេលដែល អាមេរិកាំងរៀបចំបោះឆ្នោតជ្រើសរើស ប្រធានា ធិបតី និចសុន ហើយនិង ហ៊ុមហ្វ្រី ឆ្នាំ ១៩៦៨ (1968 Presidential election Nixon & Humphrey) ។

ខ្ញុំនិងវិលត្រឡប់ មកបរិយាយឲ្យបានពិស្តា នៅលេខក្រោយ អំពីរឿងនេះ។ ខ្ញុំចង់ជុំរាបជា យ៉ាៗថា យើងមិនមែនជាអ្នកចាប់ផ្តើម ទម្លាក់រដ្ឋភិបាលយួនខាងត្បូងទេ ។ អ្នកដើមភ្លើង អ្នកដើមហេតុ បង្ករភ្លើង ឲ្យឆេះ គឺ ង៉ោឌិនយៀម ហើយនិង គឺង្វៀងវ៉ាន់ធីវ នេះឯង ។ ទាំងពីរលើកនេះ ខ្មែរក្រោមទ្រាំមិនបាន និងការជិះជាន់ធ្វើបាបនៃយួន ខ្មែរ ក៏នាំគ្នាក្រោកឈរឡើង នាំគ្នាក្រោកតែមួយព្រឹប ខ្មែរក្រោម គាស់ ពួកទ័ពយួន បាស់ជើង វាយទ័ពយួន រត់ទម្លាក់អាវុធ ចោល ថ្វីបើយួនមាន រថក្រោះ កាំភ្លើងមន្ត កាំភ្លើងធំសព្វ បែបយ៉ាង យ៉ាងច្រើនក៏ដោយ ។ បើឥតមាន អាមេរិកាំង កាន់ជើងយួន ខ្មែរក្រោម រំដោះយកកម្ពុជាក្រោម ត្រឡប់មកវិញ រួចបាត់ទៅហើយ ។

នៅចុង ឆ្នាំ ១៩៧២ លោក ម៉ែម៉េនហ្វៀល (Senate Majority leader Mike Mansfield, Democrat) ប្រធានព្រឹទ្ធសភា អាមេរិកាំង ហើយនិង លោក ហ៊្យូក ស្កុត

អនុប្រធានព្រឹទ្ធសភា (Senate Minority Leader Hugh D. Scott Jr, Republican) មកជួបសន្ទនាជាមួយ លោកប្រធានាធិបតី លន់ណល់ នៅចំពោះមុក ឧត្តមសេនីយជាន់ខ្ពស់ប្រហែល ម្ភៃនាក់ ដើម្បី ជុំរាបលោក ប្រធានាធិបតី លន់ណល់ថា កងទ័ពខ្មែរ ចំនួនពីរភាគបី លែងវាយកងទ័ពកុម្មុយនិស្ត ខ្មែរក្រហម ។

បើកងទ័ពខ្មែរមិនដូរ ឥរិយាបទនេះទេ ដើម្បីឈ្នះ កុម្មុយនិស្តនៅថ្ងៃក្រោយ អាមេរិកាំង មានផ្លូវដើរ តែមួយគត់ គឺ ទុកឲ្យខ្មែរធ្លាក់ចូល កុម្មុយនិស្ត ទុកឲ្យ ខ្មែរក្រេបរសជាតិ កុម្មុយនិស្ត ទើបថ្ងៃ ក្រោយ បានខ្មែរ ភ្ញាក់រលឹកដឹងខ្លួន នាំគ្នាស្អប់ កុម្មុយនិស្ត ។ កាលណា ប្រទេសណាមួយ បានក្រេប រសជាតិកុម្មុយនិស្តម្តងហើយ ទើបប្រទេសនោះ ខំប្រឹងប្រែងយក ជ័យជំនះ ឈ្នះកុម្មុយនិស្តបាន ។

ខ្ញុំចូលរួមសន្ទនា ជាមួយ លោកម៉ែម៉េនហ្សៀល ហើយនិង លោក ហ៊្យូក ស្កុត និងលោកប្រធានាធិបតី លន់ណល់ ក្នុងឋានៈ ខ្ញុំជាមេទ័ពកន្សែងស ម្នាក់ ។ លោក ម៉ែម៉េនហ្សៀល ហើយនិង លោក ហ៊្យូក ស្កុត និយាយស្នើ សូមលោក ប្រធានាធិបតី លន់ណល់ ឲ្យរៀបចំ កងទ័ពខេមរៈភូមិន្ទខ្មែរ សារឡើងជាថ្មី ។ អាមេរិកាំង សូមស្នើឲ្យលោក លន់ណល់ ចាត់តាំង មេបញ្ជាកន្សែងស (លោក ថាច់ប៉ូច) ឲ្យកាន់ក្តាប់ ដឹកនាំ កងទ័ពខេមរៈភូមិន្ទ ទាំងមូល ។

លោក ម៉ែម៉េនហ្សាល ហើយនិង លោក ហ៊្យូក ស្កុត និយាយបន្ថែមទៀតថា អាមេរិកាំង នឹងជួយឋវិការ មួយរយម្ភៃលានដុល្លា ប្រសិនបើ លោក លន់ណល់ តែងតាំង ពួកកន្សែងស ជាអគ្គមេបញ្ជាការ ដឹកនាំកងទ័ព ខេមរៈភូមិន្ទ ។

ពួកកងទ័ព ស៊ីហានុនិយម ដែលនៅក្នុង ជួរ កងទ័ពលោក លន់ណល់ ប្រឆាំងដាច់ខាត និងពួកកន្សែងស ដោយមាន អ៊ិនតាំ ជាមេដឹកនាំ ចេញមុខ ។ លោកអ៊ីនតាំ កាលនោះ ជានាយករដ្ឋមន្ត្រី ចង់កាន់ក្តាប់កងទ័ពនេះ ខ្លួនឯង ផ្ទាល់ ។ លោកលន់ណល់

ឆ្លើយប្រាប់ទៅលោក អ៊ិនតាំ ថា លោក ឥតចេះវិជ្ជាយោធាទេ លោក មិនអាចកាន់កងទ័ព បានទេ ។

ដោយឃើញ ពួកពួកស៊ីហានុនិយម នៅក្នុងជួរ កងទ័ពប្រចាំង ដាច់ណាត់ ដូច្នេះ ទើបលោកលន់ណល់ បង្វែររឿងនេះទៅជា បង្កើត កងទ័ពប្រជាយុទ្ធករ (Popular Forces) ទៅវិញ ។ លោកម៉ែម៉េនហ្សៀល ហើយនិង លោក ហ៊្វិក ស៊ុត យល់ព្រមតាម សេចក្តីស្នើ របស់លោកលន់ណល់ នៅក្នុង ល័ក្ខខ័ណ្ឌមួយ គឺត្រូវតែងតាំង ខ្ញុំ ជាមេដឹកនាំ កងពល ប្រជាយុទ្ធករ ។

បន្ទាប់មកទៀត លោក អ៊ិនតាំ នៅតែចចេះ ទទូចតាមសូម កាន់ទ័ពប្រជាយុទ្ធករ នេះទៀត ។ ជាទីបញ្ចប់ លោកលន់ណល់ នឿយណាយនិងលោកតាំ ក៏សុកចិត្តបណ្តោយ ឲ្យលោក អ៊ិនតាំ កាន់ទ័ពប្រជាយុទ្ធករ ។

ដោយឃើញថា គេចាត់តាំង លោកអ៊ីនតាំ ជាអ្នកទទួលខុសត្រូវនៃកងទ័ព ប្រជាយុទ្ធករ អាមេរិកាំង កាត់ជំនួយលុយ ១២០ លានដុល្លាចេញ ។ លោក អ៊ិនតាំ នៅតែ រឹងរូស បង្កើតកងទ័ពប្រជាយុត្តិករដដែល ថ្វីបើអាមេរិកាំង កាត់ជំនួយយ៉ាងដូច្នេះក៏ដោយ ។ ទិបញ្ចប់ លោកអ៊ិនតាំ រត់ចោល ពួកទ័ព ប្រជាយុទ្ធករ ៧០០០ នាក់ រត់ប្រាស់អាយុតែម្នាក់ ឯង បោះបង់ចោល កូនទាហ៊ាន នៅពេល ដែលខ្មែរក្រហមឈ្នះ ។ ខ្មែរក្រហម សម្លាប់ ចោលពួកប្រជាយុទ្ធករ ៧០០០ នាក់ ស្លាប់ទាំងអស់ ។

ពួកកងទ័ពស៊ីហានុនិយម ទាំងអស់ ត្រូវពួកយួនសម្លាប់ចោល ទាំងអស់ ដោយសារតែ ស្តេចស៊ីហានុ ចាញ់បោក យួន ឲ្យយួនយកទៅ សម្លាប់ចោល ទាំងអស់ ប្រាំសែននាក់ ។ ក្នុងមួយថ្ងៃ ជាមួយគ្នា ដោយយួនប្រើកលល្បិច ថានាំគ្នាទៅទទួល ស្តេចស៊ីហានុ ។

# កងទ័ពស៊ីហានុនិយម

## យួនខ្ចីដៃសីហនុ ដើម្បីសម្លាប់ កងទ័ពម៉ាគី (Marquis)

## សីហនុនិយមទាំងអស់ ព្រាំសែននាក់

បន្ទាប់អំពី រដ្ឋប្រហារ ទម្លាក់សម្តេចសីហនុ សម្តេចសីហនុ ចូលប័ក្សសម្ព័ន ជាមួយយួនហាណូយ ។ ស្តេចសីហនុ ដឹកនាំ កងទ័ពយួនកុម្មុយនិស្ត មកវាយ កំទិច ប្រទេសខ្មែរ ។

សម្តេចសីហនុ ប្រកាសអំពាវនាវ តាមវិទ្យុប៉េកាំង ឲ្យកូនចៅ ប្រជានុរាស្ត្រខ្មែរ ចូលព្រៃម៉ាគី (Marquis) កាន់អាវុធ វាយបន្តុំ រដ្ឋភិបាល លន់ណល់ ។

រាស្ត្រខ្មែរ ជាច្រើនស្រឡាញ់គាំទ្រ ស្តេចសីហនុ ។ កងទ័ព លោកលន់ណល់ ទាំងកងវរៈសេនា។ ព្រមទាំងកូនទាហ៊ាន នាំគ្នារត់ចូល ព្រៃម៉ាគី ចូលស្តេចសីហនុ ។ និស្សិតហើយនិង ប្រជារាស្ត្រ ជាច្រើន ចូរព្រៃម៉ាគី ចូលជាមួយស្តេចសីហនុ ។ នេះសឲ្យឃើញថារាស្ត្រ ព្រមទាំងមានអាវុទ្ធជាច្រើន ស្ម័កចិត្តបូជាជីវិត បំរើស្តេចសីហនុ ។ ក៏ប៉ុន្តែស្តេចសីហនុ មិនទុកចិត្ត ខ្មែរដែលចេះ រៀបចំ បង្កើតកងទ័ពជាតិទេ លោកមិនទុកចិត្ត មេទ័ពដែលចេះ ស្ទូទ័ព ស្ទូមនុស្សកាន់អាវុធឲ្យទៅជា កងទ័ពទេ ។

ស្តេចសីហនុ មិនខុសគ្នា ពី ពួកហ៊ុនសែន សព្វថ្ងៃនេះទេ មានទាហ៊ាន គរជើងគ្នា មានគ្រឿងសាស្ត្រាអាវុធ គរដូចភ្នំ ក៏ប៉ុន្តែ កងទ័ពគ្មានប្រសិទ្ធភាព កងទ័ពមិនចេះច្បាំង ការពារប្រទេស ។ គាត់ពូកែតែសម្លាប់ខ្មែរគ្នាឯង អត់អាវុធ ។ ដូច្នេះ ការរៀបចំ មនុស្សកាន់អាវុធ ឲ្យក្លាយទៅកងទ័ពពូកែរ ធ្លាក់ទាំងស្រុងទៅក្នុងកណ្តាប់ដៃ ពួកខ្មែរ វៀតមិញ មានន័យថា យួនហាណូយ ។ ដូច្នេះ អ្នកក្តោបក្តាប់ ពួកទ័ពសីហនុ នៅព្រៃម៉ាគី គឺយួន ហាណូយ។

ដូច្នេះ យើងអាចសន្និដ្ឋានបានថា កងទ័ពសីហនុនិយម មួយផ្នែកធំ បង្កប់នៅក្នុងជួរកងទ័ពខ្មែរក្រហម ហើយ មួយផ្នែកធំទៀត បង្កប់នៅក្នុង ជួរកងទ័ពលោក លន់ណល់ ។

ទ័ពស៊ីហានុនិយមមានច្រើនលើសលុប លើសពីទ័ពអ្នកឯងទៀត លើសលុបពី ពួកខ្មែរវៀតមិញ លើសលុបពី ពួកទ័ពខ្មែរក្រហមសុទ្ធសាធនិ៍ ហើយលើសលុបពី ពួកទ័ពលោកលន់ណល់ ។ ចំណោទរបស់ស្ដេចស៊ីហានុ ស្ថិតនៅត្រង់ លោកមិនទុកចិត្ត ពួកមេទ័ពខ្មែរ ។ លោកភ័យខ្លាច មេទ័ពខ្មែរ ក្បថលោក ធ្វើរដ្ឋប្រហារទម្លាក់លោក ។

គេសង្កេតឃើញថា ចាប់តាំងពីឆ្នាំ ១៩៧២ មក កងទ័ពជាតិ (Force Armée Nationale Khmère) នៃលោក លន់ណល់ ឈប់លែងច្បាំង ទ័ពស៊ិហានុនិយម ។ ពួកទ័ព លោក លន់ណល់នេះ បែរជានាំគ្នាពាក់ សញ្ញា រូបស៊ីហានុ នៅលើដើមទ្រូងគ្រប់ៗគ្នា លែង បាញ់ពួកកុម្មុយនិស្ត ដោយពួកទាំងអស់នេះ យល់ឃើញថាកាលណា ស្ដេចស៊ីហានុ ឈ្នះសង្គ្រាម ប្រទេសខ្មែរ និងបានសុខសាន្ត សម្បូរណ៍សប្បាយ ដូចពីដើម ។

មេទ័ពស៊ីហានុនិយម ដែលនៅបន្តប់នៅ ជាមួយទ័ពលោក លន់ណល់ ដូចជា ឧត្តមសេនីយ ឃីហាក់, ប្រាថៃប្រាឈឺន, មុំចេងអ៊ី, ហ៊ីងនួន, សមឈួន, ណុបសារ៉ី, ខួង, ញ៉ឹល, ឡេងវ៉ាអួល, អ៊ុមសារុទ ជាដើម ឈប់លែងវ៉ៃ ទ័ពស៊ីហានុ ។

មេទ័ព ដែលតាំងខ្លួនអាព្យាក្រិត្យ មិនគាំទ្រ ក៏ប៉ុន្តែ មិនប្រឆាំង និងទ័ពស៊ីហានុ មានជាដើម នរោត្តមច័ន្ទរង្សី, មូលខ្លេង, ដៀងដែល, ស្រីសាម៉ន ។

នៅក្នុងជួរ កងទ័ព លោកលន់ណល់ កងទ័ពស៊ីហានុនិយមនេះ មានចំនួន មួយសែន បីម៉ឺននាក់ មិនវ៉ៃពួកខ្មែរក្រហមទេ ច្រើនតែ ម៉ាៗយកតែរួចខ្លួន ។ ដូចជា ពួក លោក អ៊ុំសារុធ ។ ទាហ៊ានអ៊ុំសារុទ សុទ្ធតែ ពាក់រូបថតស្ដេច ស៊ីហានុទាំងអស់គ្នា។ លោក អ៊ុំសារុធ និយាយថាឲ្យ ពួកកូនទាហ៊ានគាត់ថា បើអត់មានស្ដេចស៊ីហានុ ពួកឯងទាំងអស់នេះ នៅជា ស្វាព្រៃនៅឡើយទេ ។ មេបញ្ជាការស៊ីហានុនិយម និមួយៗ នៅក្នុងជួរទ័ពលោកលន់ណល់ ប្រស្រ័យទាក់ ទងជាមួយ កងទ័ពខ្មែរក្រហម លួចឲ្យគ្រាប់ លួចប្រាប់ខ្មែរក្រហម អំពីផែនការ យុទ្ធវិធី តាក់ ទិក នៃកងទ័ពលន់ណល់ ។ នេះជាហេតុ បណ្ដាលឲ្យពួកខ្មែរក្រហម ទ្រាមចាំ

វាយច្រុក់សម្លាប់ ទាហ៊ានលោកលន់ណល់ ។ ទាហ៊ានលោកលន់ណល់ ជាច្រើនរាប់ម៉ឺន នាក់ ស្លាប់អស្សាបង់ ដោយសារ មេបញ្ជាការក្បថ ។

នៅតំបន់សឹក កំពង់ឆ្នាំង ឧត្តមសេនីយទោ អ៊ី ប្រាប់តាក់ទិក យុទ្ធវិធីរៀបចំទ័ព លោកលន់ណល់ ប្រាប់ពួកខ្មែរក្រហម ហើយ ឲ្យកាំភ្លើង AR15 ឲ្យគ្រាប់ ឲ្យសម្លៀកបំពាក់ ឯកសណ្ឋាន ឲ្យទៅពួកខ្មែរក្រហម ដើម្បីឲ្យពួកនេះ ក្លែងខ្លួន បន្លំដើរចូល មកសម្លាប់ ពួកកន្សែងស ។ ពួកកន្សែងស នឹកស្មានថាគ្នាឯង ស្មានថាជាកូនចៅលោកឧត្តមសេនីយ អ៊ី ពិព្រោះពាក់ ឯកសណ្ឋានដូច ទ៊ាហាន លន់ណល់ ហើយ កាន់កាំភ្លើង AR15 ឲ្យដើរចូល មកជិតយ៉ាង ស្រួល ចូលមកក្នុងទីតាំង ។ លុះចូលក្នុងទីតាំងរួចហើយ ខ្មែរក្រហម សម្លាប់ ពួកកន្សែងស ប្រហែល ១,០០០ នាក់ ។ ពួកកន្សែងស ចង់បាញ់ ឧត្តមសេនីយ អ៊ី ចោលនៅពេលនោះ ។ ខ្ញុំឃាត់មិនឲ្យសងសឹក ខ្ញុំគ្រាន់តែ ផ្លាស់ដក ឧត្តមសេនីយទោ (ផ្កាយ២) អ៊ី យកចេញទៅ ភ្នំពេញ ក្នុង ២៤ ម៉ោង ។

ប៉ុលពត អៀងសារី ខៀវសំផន ហើយនិង ពួកហាណូយ ហេងសំរិន ជាស៊ីម យល់ឃើញថា ក្នុងជួរកងទ័ពខ្មែរក្រហម ដែលយកជ័យជំនះ លើកងទ័ពលន់ណល់ មានពួកកងទ័ពស៊ីហានុនិយម ច្រើនណាស់ ។ កងទ័ពស៊ីហានុនិយម នេះឯងហើយ ដែល ជា គ្រោះថ្នាក់ ដ៏ធំបំផុត ចំពោះចលនា យួនកុម្មុយនិស្ត-ខ្មែរក្រហម ។ ដូច្នេះ ពួកយួន ដោយ ប្រើ ប៉ុលពត ហេងសំរិន ជាស៊ីម ជាអាយ៉ង ដើរទួរអង្គដឹកមុខ រៀបចំផែនការ សម្លាប់កង ទ័ពស៊ីហានុនិយម ទាំងអស់ចោល ។

មុនដំបូង ពួកប៉ុលពត យួនកុម្មុយនិស្ត សម្លាប់កងទ័ពស៊ីហានុនិយម មួយសែនប្រាំម៉ឺន នាក់ ដោយបញ្ឆោត ឲ្យមកទទួលអបអរសាទរ ស្តេចស៊ីហានុ ។ បន្ទាប់មក ពួកនេះ សម្លាប់ពួកអ្នករដ្ឋការ ចំនួន មួយសែននាក់ ទាំងអស់ ។ ប៉ុលពត ហើយនិង ពួកយួននេះ

សម្លាប់ពួកក្រុមគ្រួសារ នៃកងទ័ព ស៊ីហានុនិយម ទាំងអស់ ថែមទៀត បូករួមទៅ សម្លាប់ប្រហែលមួយលាននាក់ ។

ក្នុងឋានៈលោកជាប្រមុខរដ្ឋ នៃ កម្ពុជាប្រជាធិបតី ស្តេចស៊ីហានុ ប្រកាស់ ក្តែងៗ ពីទីក្រុងប៉េកាំងមក  តាមវិទ្យុខ្មែរក្រហមថា អង្គារបដិវត្តិខ្មែរក្រហម ត្រូវតែកំទិច ចោលពួករដ្ឋការ ហើយនិង ទាហ៊ានជំនាន់ចាស់ ។ មានន័យថា ទាហ៊ាន ហើយនិង រដ្ឋការទាំងអស់ គ្រប់ជាន់ថ្នាក់ តាំងតែពីតូចតាចកំប៉ិក កំប៉ុក កូនទាហ៊ាន ពួកមេដប់ខ្ទង់ អ្នករដ្ឋការទាំងអស់ ត្រូវយួនខ្មែរក្រហម យកទៅសម្លាប់ ចោលទាំងអស់ ។ ដោយគេខ្លាចពួកនេះតដៃ ឬក៏រត់ប្រសេចប្រសាច នាំឲ្យពួកវាពិបាក សម្លាប់ វាធ្វើជាថា សូមទាហ៊ាន ហើយនិង រដ្ឋការទាំងអស់គ្នា នាំគ្នាទៅ ទទួលសម្តេចឪ ប្រមុខរដ្ឋ ។ ពួកទាំងអស់នេះសុទ្ធសឹងស្រឡាញ់ គាំទ្រស្តេចស៊ីហានុ ហើយនាំគ្នាគេច មិនច្បាំង ប្រចាំងទ័ពស៊ីហានុទេ ។ ដោយប្រើស្មៀត នាំគ្នាទៅទទួលស្តេចស៊ីហានុ ខាងលើនេះ ពួកខ្មែរ ក្រហម ដែលមានយួនជាមេ សម្លាប់ ពួកទាហ៊ានស៊ីហានុនិយម រាប់សែនកនាក់ ។

បីខែក្រោយមក ពួកខ្មែរក្រហម យួន ចាប់អនុវត្តិ នយោបាយមួយទៀត គឺ នយោបាយរំសាយពួកទាហ៊ានជាប់ប្រវត្តិ ។ ពួកទាហ៊ានជាប់ប្រវត្តិនេះ គឺពួកយោធាខ្មែរក្រហម ដែលបានច្បាំងក្នុងជួរខ្មែរក្រហម ក៏ប៉ុន្តែ មានម៉ែឪ ឬកូនចៅ ជាទាហ៊ាន ឬរដ្ឋការជំនាន់ចាស់ ។ ពួកខ្មែរក្រហម យួននេះ សម្លាប់ ពួកយោធាជាប់ប្រវត្តិនេះព្រមទាំង គ្រួសារ ទាំងអស់គ្មានសល់ ។ បូករួមទៅ ពួកខ្មែរក្រហម យួនសម្លាប់ចោលរាប់លាននាក់ ។

## **ចៅដារា អគ្គមេបញ្ជា កន្សែងស ក្អែកខ្មៅ**